ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

អ សិ ផ ស

# របាយការណ៍បូកសរុបលទ្ធផល
# ការងារសុខភាពសត្វ និងផលិតកម្មសត្វ
# ទូទាំងប្រទេសប្រចាំឆ្នាំ២០១៦
# និងទិសដៅអនុវត្តការងារឆ្នាំ២០១៧

ខែកុម្ភៈ ឆ្នាំ២០១៧

ឧបត្ថម្ភបោះពុម្ពដោយកម្មវិធី EU.PGA.L

ភូមិទ្រា ផ្លូវលេខ៣៧១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
Trea Village, Str.371, Sangkat Steung Mean Chey, Khan Mean Chey, Phnom Penh Cambodia
ទូរស័ព្ទលេខៈ(៨៥៥) ២៣៨៨៣ ៧៤៦/៨៨៤ ១៤៨ ទូរសារៈ(៨៥៥)២៣៨៨៣៧៤៦/៨៨៤ ១៤៨
Tel: (855) 23 883 746 /884 148 Fax: (855) 23 883 746/884 148

# មាតិកា


I-**សេចក្តីផ្តើម**............................................................................................................ 1

II-**គោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ**.. 2

១-យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាល ២០១៤-២០១៨........................2

២-ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨.............................................2

៣-ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ២០១៦-២០២៥..................................3

៤-ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥.....3

III-**លទ្ធផលជារួម**........................................................................................................ 4

IV-**លទ្ធផលជំរុញផលិតកម្មសត្វ និងសុខភាពសត្វ**................................................................ 5

១. ការពង្រឹងសមត្ថភាពអង្គភាព សេវាគាំទ្រ និងការអភិវឌ្ឍធនធានមនុស្ស................................ 5

២-ការជំរុញផលិតកម្មសត្វ និងបង្កើនផលិតភាពសត្វ............................................................ 7

៣- ការលើកកម្ពស់សុខភាពសត្វ និងសុខភាពសាធារណៈ.......................................................19

៤.ការផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម ........................................................................ 23

៥-ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ ........................................ 24

V-**ភាពលទ្ធភាព និងបញ្ហាប្រឈម**..................................................................................... 25

VI-**ទិសដៅអនុវត្តឆ្នាំ ២០១៧-២០១៨**................................................................................ 26

VII-**សេចក្តីសន្និដ្ឋាន**...................................................................................................... 28

# របាយការណ៍បូកសរុប
# ការងារសុខភាពសត្វ និងផលិតកម្មសត្វប្រចាំឆ្នាំ ២០១៦-២០១៧
# និងទិសដៅអនុវត្តឆ្នាំ ២០១៧-២០១៨

## I-សេចក្តីផ្តើម

អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វមានសក្តានុពលក្នុងការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ច ការងារ សន្តិសុខស្បៀង អាហាររូបត្ថម្ភ និងកាត់បន្ថយគំលាតចំណូលរវាងអ្នកទីក្រុង និងអ្នកជនបទ។ ប៉ុន្តែ អនុវិស័យនេះ នៅមិនទាន់បានប្រើប្រាស់អស់សក្តានុពលនៅឡើយ។ ៨០% នៃអ្នកចិញ្ចឹមសត្វ នៅបន្តចិញ្ចឹម ជាលក្ខណៈគ្រួសារ ខ្នាតតូច ដែលបែបផែនផលិតកម្មនេះមានបញ្ហាប្រឈមមួយចំនួន ដោយសារការគ្រប់គ្រង និងចាត់ចែងក្នុងការ ចិញ្ចឹមមិនបានល្អ ដែលតែងតែមានការឆ្លងរាលដាលជំងឺ អត្រាសត្វឈឺ និងងាប់ខ្ពស់ ការចំណាយថ្លៃដើមផលិតកម្មក៏ខ្ពស់ រួមជាមួយនឹងគុណភាពផលិតផលមិនស្របតាមតម្រូវការទីផ្សារ។ ជាលទ្ធផល មិនទាន់អាច ប្រកួតប្រជែងជាមួយសត្វ និងផលិតផលសត្វនាំចូល ឬការចិញ្ចឹមជាលក្ខណៈឧស្សាហកម្ម។

ដោយទទួលស្គាល់នូវសក្តានុពលនៃអនុវិស័យនេះ ក៏ដូចជាដោះស្រាយនូវឧបសគ្គមួយចំនួន ដែលរាំងស្ទះដល់ការអភិវឌ្ឍន៍ រាជរដ្ឋាភិបាល ក្នុងនិតិកាលទី៥ នេះ បានដាក់ចេញនូវគោលដៅជំរុញលើកម្ពស់ការចិញ្ចឹមសត្វ ឲ្យកាន់តែទូលំទូលាយថែមទៀត តាមរយៈការបង្កើតក្របខ័ណ្ឌគោលនយោបាយ ដោយផ្អែកលើខ្សែសង្វាក់តម្លៃ ដើម្បីដោះស្រាយជាកញ្ចប់នូវបញ្ហាជាឧបសគ្គដល់ការអភិវឌ្ឍអនុវិស័យនេះ ដោយគិតគូផងដែរដល់បញ្ហាសុវត្ថិភាពចំណីអាហារ និងកិច្ចដំណើរការទីផ្សារ ពិសេសអនាម័យ និងភូតគាមអនាម័យ។

ឆ្លើយតបនឹងគោលដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់បញ្ចូលការលើកកម្ពស់ការចិញ្ចឹមសត្វទៅក្នុងផែនការអភិវឌ្ឍវិស័យកសិកម្មឆ្នាំ២០១៤-២០១៨ រួមជាមួយនឹងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ពង្រឹង និងបង្កើនការផ្តល់សេវាកម្មសុខភាពសត្វនិងផលិតកម្មសត្វ រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា គម្រោង និងកម្មវិធីសម្រាប់ប្រើប្រាស់ថវិកាតាមកម្មវិធី ក៏ដូចជាសម្រាប់ដាក់ស្នើសុំការគាំទ្រពីដៃគូអភិវឌ្ឍនានា និងដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីសម្របសម្រួលការងារអនុវត្តច្បាប់ និងយុទ្ធសាស្ត្រពាក់ព័ន្ធ និងដើម្បីលើកទឹកចិត្តជំរុញការវិនិយោគលើអនុវិស័យនេះ តម្រង់ទិសការអភិវឌ្ឍតំបន់កែច្នៃផលិតផលសត្វ ជាលក្ខណៈប្រមូលផ្តុំ ដែលមានសក្តានុពលសម្រាប់កែច្នៃប្រើប្រាស់ក្នុងស្រុក និងនាំចេញ។ យន្តការគន្លឹះដែលត្រូវយកចិត្តទុកដាក់ក្នុងកម្មវិធីការអភិវឌ្ឍនេះគឺ ការសម្របសម្រួល និងការលើកទឹកចិត្តវិស័យឯកជន ក្នុងការអភិវឌ្ឍបច្ចេកទេសកែច្នៃផលិតផលសត្វ ស្របតាមស្តង់ដារផលិតផលអាស៊ាន និងតម្រូវការស្តង់ដារទីផ្សារអន្តរជាតិ។ ការផ្សារភ្ជាប់រវាងក្រុមអ្នកផលិត ជាមួយអ្នកប្រមូលទិញ តាមយន្តការ "ផលិតកម្មកសិកម្មតាមកិច្ចសន្យា" ដើម្បីធានាការផ្គត់ផ្គង់សត្វ សាច់សត្វប្រកបដោយនិរន្តរភាព និងគុណភាព គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់ ដែលត្រូវបានយកចិត្តទុកដាក់។

លទ្ធផលដែលសម្រេចបាននេះ អាស្រ័យមានគោលនយោបាយគាំទ្ររបស់រាជរដ្ឋាភិបាល មានការគាំទ្រធនធានថវិកាជាតិ ដៃគូអភិវឌ្ឍ អង្គការជាតិ និងអន្តរជាតិ វិស័យឯកជន ជាមួយនឹងការខិតខំរបស់អង្គភាពជំនាញគ្រប់កម្រិត ដោយមានកិច្ចសហការពីអាជ្ញាធរមូលដ្ឋាន និងសហគមន៍អ្នកចិញ្ចឹមសត្វ។

## II-គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសុខភាពសត្វ និងផលិតកម្មសត្វ

### ១.យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល២០១៤-២០១៨

រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់នូវសក្តានុពលនៃអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងការចូលរួមក្នុងកម្មវិធីលើកកម្ពស់អាហារូបត្ថម្ភ ការបង្កើនចំណូលរបស់ប្រជាពលរដ្ឋ និងការបម្រើសេចក្តីត្រូវការទាំងក្នុងស្រុក និងក្រៅស្រុក។

ដើម្បីឲ្យសក្តានុពលរបស់អនុវិស័យនេះ អាចក្លាយជាប្រយោជន៍ពិតសម្រាប់ប្រជាពលរដ្ឋ សហគមន៍ អ្នកចិញ្ចឹមសត្វ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល បានដាក់ចេញនូវទិសដៅធំៗ ចំនួន៤ គឺ៖

ទី១. ជំរុញការរៀបចំ និងដាក់ឲ្យអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រលើកកម្ពស់ការចិញ្ចឹមសត្វ។

ទី២. ជំរុញការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍលើការបង្កាត់ពូជ ការគ្រប់គ្រងសុខភាពសត្វ ការផលិតចំណីសត្វ និងប្រព័ន្ធកសិដ្ឋាន។

ទី៣.ការជំរុញអនុម័តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំស្ថាប័ន និងគ្រប់គ្រង ក្នុងគោលដៅពង្រឹងការអនុវត្តស្តង់ដារអនាម័យលើផលិតផលពីសត្វ ការពង្រឹង និងការអនុវត្តវិធានការអនាម័យ ភូតគាមអនាម័យ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ ក៏ដូចជាដើម្បីការពារសុខភាពសាធារណៈ។

ទី៤. ការជំរុញលើកទឹកចិត្តការវិនិយោគលើការផលិតចំណីសត្វ ក្នុងទ្រង់ទ្រាយមធ្យម និងធំ ដើម្បីគាំទ្រដល់ចលនាចិញ្ចឹមសត្វ រួមជាមួយនឹងការលើកកម្ពស់ប្រព័ន្ធផ្តល់សេវាបច្ចេកទេស ពូជ ឥណទាន និងការសម្របសម្រួលទីផ្សារជូនកសិករ ការលើកទឹកចិត្តការវិនិយោគឯកជនក្នុងការកែច្នៃផលិតផលសត្វ ការបង្កើតសត្តឃាតដ្ឋានទំនើប ព្រមទាំងការសម្រួលពាណិជ្ជកម្មលើសត្វ និងផលិតផលសត្វ។

### ២.ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម២០១៤-២០១៨

ដើម្បីសម្រេចបាននូវទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម២០១៤-២០១៨។ ផែនការនេះ បានកំណត់ទិសដៅគោលនយោបាយរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់អនុវត្តរយៈពេលប្រាំឆ្នាំគឺ “ជំរុញកំណើនវិស័យកសិកម្មប្រចាំឆ្នាំឲ្យបានក្នុងរង្វង់៥% តាមរយៈការលើកកម្ពស់ផលិតភាព ពិពិធកម្មភាវូបនីយកម្ម និងពាណិជ្ជនីយកម្មកសិកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារ និងគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយនិរន្តរភាព”។

ទន្ទឹមនឹងនេះ ដើម្បីសម្រេចបាននូវកំណើននេះ ទាមទាឲ្យស្ថាប័នមានលទ្ធភាព និងសមត្ថភាពខ្ពស់ ទាំងធនធានមនុស្ស និងថវិកា។ ឈរលើមូលដ្ឋាននៃការគិតគូនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំ និងដាក់ចេញនូវកម្មវិធីជាយុទ្ធសាស្ត្រចំនួន៥គឺ៖

*កម្មវិធីទី១៖ បង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម*

*កម្មវិធីទី២៖ ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ*

*កម្មវិធីទី៣៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព*

*កម្មវិធីទី៤៖ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព*

*កម្មវិធីទី៥៖ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ។*

កម្មវិធីអាទិភាពមួយរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម២០១៤-២០១៨ គឺកម្មវិធីជំរុញសុខភាពសត្វ និងផលិតកម្មសត្វ ដែលស្ថិតក្នុងលំដាប់ថ្នាក់អាទិភាពទីពីរនៃរបៀបវារៈជំរុញកំណើនវិស័យកសិកម្ម។ កម្មវិធីនេះត្រូវបង្កើនចំនួនសត្វចិញ្ចឹមឲ្យបាន៣% ក្នុងមួយឆ្នាំ តាមរយៈការពិសោធស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសប្រកបដោយប្រសិទ្ធភាព ការបង្កើនសមត្ថភាពបង្ការ ទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺស៊ូណូសដើម្បីធានាការផ្គត់ផ្គង់សត្វ និងផលិតផលសត្វ ប្រកបដោយអនាម័យ សុវត្ថិភាព ឈានទៅបង្កើនសក្តានុភាពនៃការនាំចេញ។ កម្មវិធីនេះ គាំទ្រដោយអនុកម្មវិធីចំនួន៩ ដែលបានការគាំទ្រថវិកាពីរដ្ឋាភិបាល។

## ៣.ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបសុសត្វ២០១៦-២០២៥

ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វឆ្នាំ២០១៦-២០២៥ បានដាក់ឲ្យអនុវត្តនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦។ ចក្ខុវិស័យនៃក្របខ័ណ្ឌផែនការនេះ គឺការអភិវឌ្ឍវិស័យបសុសត្វប្រកបដោយនិរន្តរភាពធានាបាននូវសន្តិសុខស្បៀង សុវត្ថិភាពចំណីអាហារ និងការធ្វើពាណិជ្ជកម្មប្រកបដោយប្រាក់ចំណេញ និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចសង្គមជាតិ។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រនេះ ជំរុញឱ្យមានការអនុវត្តសុខភាពសត្វ និងផលិតកម្មសត្វល្អតាមរយៈការអភិវឌ្ឍធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ការស្រាវជ្រាវ និងផ្សព្វផ្សាយ ការរៀបចំគោលនយោបាយ និងពង្រឹងការអនុវត្តច្បាប់ ការអភិវឌ្ឍភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ព្រមទាំងការប្រាស្រ័យទាក់ទង។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រនេះ មានទិសដៅអាទិភាពចំនួន៨គឺ៖

១. ពង្រឹងផលិតកម្មសត្វ រួមទាំងលើកកម្ពស់ការគ្រប់គ្រង និងការបង្កាត់ពូជសត្វ។
២. ពង្រឹងសុខភាពសត្វ សុខភាពសាធារណៈបសុព្យាបាល និងសុខុមាលភាពសត្វ។
៣. លើកកម្ពស់ការផ្សព្វផ្សាយច្បាប់ ការពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយនានា។
៤. ជំរុញការស្រាវជ្រាវ និងការអភិវឌ្ឍស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។
៥. បង្កើនការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្សនៅក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។
៦. លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន នៅក្នុងវិស័យអភិវឌ្ឍន៍បសុសត្វ។
៧. ពង្រឹងសេវាផ្សព្វផ្សាយស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងការអភិវឌ្ឍទីផ្សារ។
៨. ពង្រឹងកិច្ចសហប្រតិបត្តិការទាំងផ្នែកសេដ្ឋកិច្ច និងបច្ចេកទេសកម្រិតជាតិ និងអន្តរជាតិលើអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

## ៤. ផែនការសកម្មភាព សម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥

រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការនូវ"គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥"នៅដើមខែមិថុនា ឆ្នាំ២០១៥ កន្លងទៅនេះ ដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មកម្ពុជា ដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្នតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងការប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។

ចំណុចគន្លឹះពាក់ព័ន្ធនឹងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ គឺការតម្រង់ទិសការអភិវឌ្ឍតំបន់កែច្នៃផលិតសត្វជាលក្ខណៈប្រមូលផ្តុំ ដែលមានសក្តានុពលសម្រាប់កែច្នៃប្រើប្រាស់ក្នុងស្រុកនិងនាំចេញ។ យន្តការគន្លឹះដែលត្រូវយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍកសិឧស្សាហកម្មនោះគឺការសម្របសម្រួល និងការលើកទឹកចិត្តវិស័យឯកជន ក្នុងការអភិវឌ្ឍបច្ចេកទេសកែច្នៃផលិតកម្មសត្វស្របតាមស្តង់ដារផលិតផលអាស៊ាន និងតម្រូវការ

ស្តង់ដារទីផ្សារអន្តរជាតិ។ ការផ្សារភ្ជាប់រវាងក្រុមអ្នកផលិតជាមួយអ្នកប្រមូលទិញតាមយន្តការ "ផលិតកម្មកសិកម្មតាមកិច្ចសន្យា" ដើម្បីធានាការផ្គត់ផ្គង់កសិផលប្រកបដោយនិរន្តរភាព គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់ផងដែរ។

បន្ថែមលើសពីនេះទៀត ការលើកកម្ពស់វិធានអនាម័យ និងភូតគាមអនាម័យ ក៏បានត្រូវយកចិត្តទុកដាក់លើការកសាងក្របខ័ណ្ឌគតិយុត្ត និងបច្ចេកវិទ្យា ព្រមទាំងពង្រីកនិងពង្រឹងសមត្ថកិច្ចត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យនៅតាមច្រកព្រំដែន ដើម្បីសម្រួលពាណិជ្ជកម្ម សមាហរណកម្មសេដ្ឋកិច្ច និងទទួលបានទីផ្សារផលិតផលកសិកម្មក្នុងតំបន់ និងអន្តរជាតិ។

## III-លទ្ធផលជារួម

នាឆ្នាំ២០១៦ នេះ ផលិតកម្មសត្វ ដែលជាផ្នែកមួយសំខាន់នៃសូចនាករគោល ក៏បានសម្រេចលើសពីចំណុចដៅដោយសម្រេចបាន៣,៥១% បើធៀបនឹងឆ្នាំ២០១៥ ចំនួនសត្វសរុប៤០.៣០៩.៦៨៤ក្បាល និងនៅឆ្នាំ២០១៦ ដល់កើនដល់៤២.១៨៣.៣៩៤ ក្បាល ក្នុងនោះគោកើនឡើង០,១២% ក្របីកើនឡើង៣,៤១% ជ្រូកកើនឡើង៧,០៧% និងបក្សីកើនឡើង៣,៥២% ដោយឡែកកម្លាំងអូសទាញថយចុះ៧,១១%។ គួរគូសបញ្ជាក់ផងដែរថា នេះជាឆ្នាំទីមួយដែលចំនួនក្របីបានកើនឡើងវិញ បន្ទាប់ពីមានការធ្លាក់ជាច្រើនឆ្នាំជាប់ៗគ្នា។

នៅឆ្នាំ២០១៦ នេះ ថ្វីបើមានផ្ទុះជំងឺឆ្លងសត្វជាច្រើនករណី ប៉ុន្តែមិនបណ្តាលឲ្យឆ្លងរាលដាលធ្ងន់ធ្ងរអាស្រ័យដោយមានការត្រៀមទុកជាមុនក្នុងការឆ្លើយតបបន្ទាន់ករណីផ្ទុះជំងឺសត្វ។

អាស្រ័យដោយការខិតខំប្រឹងប្រែងអនុវត្តតួនាទីភារកិច្ច រួមផ្សំនឹងការគាំទ្រពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការជាតិ និងអន្តរជាតិ ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា អង្គភាពជំនាញសុខភាពសត្វ និងផលិតកម្មសត្វ សម្រេចបាននូវសមិទ្ធផលសំខាន់ៗ មួយចំនួន ក្នុងនោះរួមមាន៖

១-បានទទួលការអនុម័ត និងដាក់ឲ្យអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

២-បានទទួលការអនុម័ត និងដាក់ឲ្យអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ ២០១៦-២០២៥។

៣-បានទទួលការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលទៅជាអគ្គនាយដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

៤.សេចក្តីព្រាងផែនការជាតិលុបបំបាត់ជំងឺអុតក្តាមក្នុងក្របខ័ណ្ឌអនុតំបន់នៃការលុបបំបាត់ជំងឺអុតក្តាម។

ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ និងលិខិតបទដ្ឋានពាក់ព័ន្ធមួយចំនួនត្រូវបានបោះពុម្ព និងផ្សព្វផ្សាយដល់ក្រសួង ស្ថាប័នជាតិ អង្គការជាតិ និងអន្តរជាតិ រដ្ឋាភិបាល ដៃគូអភិវឌ្ឍនានា រួមទាំងអាជីវករ ផលិតករ ដែលមានសកម្មភាពពាក់ព័ន្ធនឹងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ព្រមទាំងបានធ្វើបង្ហាញពីការចិញ្ចឹមសត្វ តាមលក្ខណៈបច្ចេកទេសនៅគ្រប់ ២៥ រាជធានី-ខេត្ត។

ទម្លាប់នៃការចិញ្ចឹមសត្វរបស់កសិករក៏បានកែជាបណ្តើរៗ ពីការចិញ្ចឹមសម្រាប់តែតម្រូវការក្នុងគ្រួសារពី ២ ទៅ៣ក្បាល ក្នុងមួយគ្រួសារ មកជាការចិញ្ចឹមស្របតាមបទដ្ឋានបច្ចេកទេស និងជាលក្ខណៈឧស្សាហកម្ម។

## IV-លទ្ធផលជំរុញផលិតកម្មសត្វ និងសុខភាពសត្វ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មានតួនាទីជានាគ្រប់គ្រង និងអភិវឌ្ឍអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ការពារសុខភាពមនុស្ស សុខភាពសត្វ សុខុមាលភាពសត្វ និងការពារបរិស្ថាន បង្ការទប់ស្កាត់ លុបបំបាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វ ការពារធនធានសត្វ និងពូជសត្វរបស់ជាតិ ព្រមទាំងធានានូវនិរន្តរភាពនៃការផ្គត់ផ្គង់ផលិតផលសត្វ ប្រកបដោយគុណភាព និងសុវត្ថិភាព សម្រាប់ទីផ្សារក្នុងស្រុក និងការនាំចេញ។ លទ្ធផលសំខាន់ៗ សម្រាប់ឆ្នាំ២០១៦ រួមមាន៖

## ១. ការពង្រឹងសមត្ថភាពអង្គភាព សេវាគាំទ្រ និងការអភិវឌ្ឍធនធានមនុស្ស

### ១.១. ការគ្រប់គ្រងធនធានមនុស្ស

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មាននាយកដ្ឋានចំនួន៤ និងវិទ្យាស្ថានចំនួន១ គឺ នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ នាយកដ្ឋានផលិតកម្មសត្វ នាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល និងនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេសនិងនីតិកម្ម និងវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វនិងផលិតកម្មសត្វ ដែលមានមន្ត្រីបម្រើការងារចំនួន៨៦៩នាក់ ក្នុងនោះស្រី ១៩០នាក់ ដែលចែកចេញជាមន្ត្រីថ្នាក់កណ្តាល២៦១នាក់ ស្រី៨៣នាក់ និងរាជធានី-ខេត្ត៦០៨នាក់ ស្រី ១០៧នាក់។ (ឧបសម្ព័ន្ធទី ១)

**តារាងស្ថិតិមន្ត្រីបម្រើការងារក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ទាំងថ្នាក់ជាតិ និងរាជធានី-ខេត្ត**

| ល.រ | កម្រិតជំនាញបច្ចេកទេស | មន្ត្រីអគ្គនាយកដ្ឋាន | | មន្ត្រីរាជធានី-ខេត្ត | | សរុប (នាក់) | |
|---|---|---|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៥ | ២០១៦ | ២០១៥ | ២០១៦ |
| ១ | ថ្នាក់បណ្ឌិត | ០៨ | ០៨ | ០ | ០ | ០៨ | ០៨ |
| ២ | ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ | ៣៤ | ៤០ | ៣៣ | ៣៩ | ៦៧ | ៧៩ |
| ៣ | ថ្នាក់បរិញ្ញាប័ត្រ | ១២៧ | ១៣២ | ២០៣ | ២២៣ | ៣៣០ | ៣៥៥ |
| ៤ | ថ្នាក់បរិញ្ញាប័ត្ររង | ៥១ | ៥៥ | ១៩៦ | ២០៤ | ២៤៧ | ២៥៩ |
| ៥ | ថ្នាក់បឋម | ០៥ | ០៥ | ១១៤ | ៨៦ | ១១៩ | ៩១ |
| ៦ | បុគ្គលិក | ២២ | ២១ | ៦២ | ៥៦ | ៨៤ | ៧៧ |
| សរុបរួម | | ២៤៧ | ២៦១ | ៦០៨ | ៦០៨ | ៨៥៥ | ៨៦៩ |

**តារាងស្ថិតិមន្ត្រីបម្រើការងារនៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ**

| | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ | ប្រុស | ស្រី | សរុប |
|---|---|---|---|---|
| 1 | ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន | ៥ | ១ | ៦ |
| 2 | នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យនិងសហប្រតិបត្តិការ | ៣៨ | ២១ | ៥៩ |
| 3 | នាយកដ្ឋានផលិតកម្ម | ២៦ | ១៤ | ៤០ |
| 4 | នាយកដ្ឋានសុខភាពសត្វនិងសុខភាពសាធារណៈបសុព្យាបាល | ៤៧ | ១៦ | ៦៣ |
| 5 | នាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេសនិងនីតិកម្ម | ២៥ | ១០ | ៣៥ |
| 6 | វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ ស្ថានីយ | ៣៧ | ២១ | ៥៨ |
| | **សរុប** | ១៧៨ | ៨៣ | ២៦១ |

### ១.២. ការអភិវឌ្ឍធនធានមនុស្ស

ឆ្លើយតបនឹងការកំណត់អាទិភាពការអភិវឌ្ឍធនមនុស្ស របស់រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានបង្កើនសមត្ថភាពមន្ត្រីជាបន្តបន្ទាប់ ទាំងសមត្ថភាពរៀបចំ និងអនុវត្តផែនការ និងសមត្ថភាព បច្ចេកទេសសម្រាប់ផ្តល់ សេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វឲ្យកាន់ តែប្រសើរថែមទៀត។ដោយបានគៀងគរជំនួយ និងការគាំទ្រនានា ពីដៃគូអភិវឌ្ឍន៍ ពីរដ្ឋាភិបាល សម្រាប់គាំទ្រដល់ការបង្កើនសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធ តាមរយៈការបណ្តុះបណ្តាលសិក្ខាសាលា និងកិច្ចប្រជុំនានា ទាំងក្នុងនិងក្រៅប្រទេសសរុបបានចំនួន២.៥៩៥ លើក។

### ១.៣. ការប្រមូលកម្រៃសេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ

សេវាកម្មសំខាន់ៗ ដែលអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បាន និងកំពុងអនុវត្ត រួមមានការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យសត្វ និងផលិតផលសត្វ ការចេញលិខិតអនុញ្ញាតធ្វើ អាជីវកម្មសត្វ និងផលិតផលសត្វ ការវិភាគគុណភាពចំណីសត្វ បសុឱសថ សាច់ ការផ្តល់លិខិតអនុញ្ញាតធ្វើចរាចរសត្វ និងផលិតផលសត្វ ការអនុញ្ញាតនាំចេញ នាំចូលសត្វរស់ និងផលិតផលសត្វ សម្ភារ បរិក្ខាបសុពេទ្យ ការចេញលិខិតអនុញ្ញាតសម្រាប់បង្កើតសត្តឃាតដ្ឋាន និងកសិកដ្ឋានចិញ្ចឹមសត្វ។ល។សរុបនៅក្នុងឆ្នាំ២០១៦ នេះ រួមទាំងលិខិតចេញ និងចូលមានចំនួន៨.៥៥៥ច្បាប់។

នាឆ្នាំ២០១៦ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វនិងការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី-ខេត្ត ប្រមូលចំណូលបានសរុប**៧.៤២៣.៥៧៧.១៧២** រៀល។ បើប្រៀបធៀបចំណូល ឆ្នាំ២០១៥ ក្នុងរយៈពេលដូចគ្នា ឃើញថាកើនឡើង៦.៧២% ក្នុងនោះចំណូលថ្នាក់កណ្តាល កើន ៣.០៣ % ចំណូលរាជធានី-ខេត្តកើន១៣.១៥%។

**តារាងប្រៀបធៀបចំណូលសេវាកម្មសុខភាពសត្វនិងផលិតកម្មសត្វពីឆ្នាំ២០១២ដល់ឆ្នាំ ២០១៦**

| អង្គភាព | 2012 | 2013 | 2014 | 2015 | 2016 | ប្រៀបធៀប 2015និង2016 |
|---|---|---|---|---|---|---|
| អ.ស.ផ.ស | 3.243.658.909 | 2.802.534.974 | 3.783.478.997 | 4.416.812.844 | 4.550.480.122 | 3,03 |
| រាជធានី-ខេត្ត | 2.022.299.100 | 204.908.600 | 1.530.633.094 | 2.539.247.800 | 2.873.097.050 | 13,15 |
| សរុប | 5.265.958.009 | 3.007.443.574 | 5.314.112.091 | 6.956.060.644 | 7.423.577.172 | 6,72 |

**ក្រាហ្វិកប្រៀបធៀបចំណូលសេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ ពីឆ្នាំ២០១២-២០១៦**



អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ សម្រេចបានការងាររៀបចំផែនការសំខាន់ៗ មួយចំនួនក្នុងនោះរួមមាន៖

១. ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបសុសត្វ រយៈពេល ១០ ឆ្នាំ ២០១៦-២០២៥។

២.ធ្វើបច្ចុប្បន្នភាពផែនការសម្រាប់អនុវត្តថវិកាតាមកម្មវិធីរបស់រាជរដ្ឋាភិបាល៖ បានរៀបចំ និងអនុវត្តកម្មវិធីទី២ នៃកម្មវិធីអាទិភាពរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម ២០១៤-២០១៨។

៣. ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨៖ បានធ្វើបច្ចុប្បន្នភាពអនុកម្មវិធីពី៩ មក៥។

៤. ផែនការជាតិលុបបំបាត់ជំងឺអុតក្តាមក្នុងក្របខ័ណ្ឌអនុតំបន់ នៃការលុបបំបាត់ជំងឺអុតក្តាម។

៥. ផែនការសកម្មភាពបញ្ច្រាបយេនឌ័រក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

### ១.៥ ការងារសហប្រតិបត្តិការអន្តរជាតិ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានា អង្គការជាតិ អង្គការអន្តរជាតិមានដូចជាៈសហភាពអឺរ៉ុប អង្គការសុខភាពសត្វពិភពលោកអង្គការស្បៀង និងកសិកម្មសហប្រជាជាតិ ACIAR, IAEA, JICA, KOIKA, AVSF, PIN, VSO, 2KR, UNIDO។

## ២-ការជំរុញផលិតកម្មសត្វ និងបង្កើនផលិតភាពសត្វ

សូចនាករសម្មិតកម្មគន្លឹះនៃកម្មវិធីជំរុញផលិតកម្មសត្វ និងសុខភាពសត្វ គឺសម្រេចឲ្យបាននូវកំណើនសត្វចិញ្ចឹមគ្រប់ប្រភេទក្នុងអត្រា៣ % ក្នុងមួយឆ្នាំ ដោយផ្អែកលើប្រសិទ្ធភាពនៃការពិសោធន៍ស្រាវជ្រាវ និងផ្សព្វផ្សាយ ការបង្កើនសមត្ថភាពបង្ការទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺស៊ូណូស៊ីស ការធានាការផ្គត់ផ្គង់សត្វផលិតផលសត្វប្រកបដោយអនាម័យ សុវត្ថិភាព និងបង្កើនសក្តានុភាពនៃការនាំចេញ។

### ២.១ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ និងកសិដ្ឋានខ្នាតតូច

តារាងខាងក្រោមបង្ហាញពីវឌ្ឍនភាពនៃការចិញ្ចឹមសត្វជាលក្ខណៈគ្រួសាររយៈពេលប្រាំឆ្នាំ គិតចាប់ពីឆ្នាំ២០១២ដល់ឆ្នាំ២០១៦។ តួរលេខក្នុងតារាងនេះបានឲ្យដឹងថាចំនួនសត្វចិញ្ចឹមគ្រប់ប្រភេទជាលក្ខណៈគ្រួសារបានកើនជាលំដាប់ពី២៥.៣៨០.២៣៧ ក្បាល នៅឆ្នាំ២០១២ ដល់៣៨.២២៣.០០៧ ក្បាល នៅឆ្នាំ២០១៦ កើនប្រមាណ១២.៥៦៦.០៤០ ក្បាល ស្មើនឹង៤២%។ ដោយឡែកបើធៀបនឹងឆ្នាំ២០១៥ កើនប្រមាណ ១.៤៣០.០០០ ក្បាល ស្មើនឹង៥,៣៤% ក្នុងនោះជ្រូកកើន០,៥៧ % បក្សីកើន៦,៤២ % ក្របីកើន៣,៤១ % តែគោថយចុះ០,២២ % និងគោ ក្របីកម្លាំងអូសទាញថយចុះ៧,១ %។ (ឧបសម្ព័ន្ធទី២ និងទី៣)

**ស្ថិតិសត្វចិញ្ចឹមជាលក្ខណៈគ្រួសារ ឆ្នាំ២០១២-២០១៦**

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វប្រាំឆ្នាំចុងក្រោយ (២០១២-២០១៦) | | | | | ប្រៀបធៀបឆ្នាំ |
|---|---|---|---|---|---|---|---|
| | | 2012 | 2013 | 2014 | 2015 | 2016 | 2015និង 2016 |
| A | B | 2 | 3 | 4 | 5 | 6 | 7=6/5 |
| 1 | គោ | 3.372.212 | 3.425.952 | 3.053.481 | 2.903.420 | 2.897.126 | -0,22% |
| 2 | ក្របី | 656.938 | 619.114 | 541.827 | 506.165 | 523.320 | 3,39% |
| 3 | គោ-ក្របី | 4.029.150 | 4.045.066 | 3.595.308 | 3.409.585 | 3.420.446 | 0,32% |
| 4 | កម្លាំងអូសញ | 1.516.110 | 1.344.541 | 1.249.817 | 1.132.097 | 1.051.625 | -7,11% |
| 5 | ជ្រូក | 1.952.321 | 2.067.975 | 2.360.823 | 2.357.839 | 2.371.283 | 0,57% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 6 | បក្សី | 19.374.139 | 21.429.519 | 25.630.027 | 26.688.675 | 28.402.486 | 6,42% |
| 7 | សេះ | 12.394 | 10.850 | 9.161 | 7.637 | 5.610 | -26,54% |
| 8 | ចៀម | 174 | 100 | 238 | 378 | 400 | 5,82% |
| 9 | ពពែ | 11.995 | 15.831 | 18.256 | 23.321 | 22.719 | -2,58% |
| 10 | ដំរី | 64 | 64 | 63 | 64 | 63 | -1,56% |
| | សរុប | 25.380.237 | 27.569.405 | 31.613.876 | 32.487.499 | 34.223.007 | 5,34% |

## ២.២ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម

តារាងខាងក្រោមបង្ហាញពីវឌ្ឍនភាពនៃផលិតកម្មសត្វជាលក្ខណៈពាណិជ្ជកម្មចាប់ពីឆ្នាំ២០១៥-២០១៦។ តាមតួរលេខក្នុងតារាងនេះបានឲ្យដឹងថា ចំនួនសត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម មានការថយចុះចំនួន ៣,០៧%។ ការថយចុះនេះ បណ្តាលមកពីមានការថយចុះចំនួនបក្សីរហូតដល់ ៦,៣៧ % ចំណែកឯគោ-ក្របី កើនឡើង៧៦ % ជ្រូក កើន៤៤ %។

**តារាងស្ថិតិសត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០១៥-២០១៦**

| ប្រភេទសត្វ | ឆ្នាំ២០១៥ | | ឆ្នាំ២០១៦ | | ប្រៀបធៀបឆ្នាំ២០១៥-២០១៦ | | | |
|---|---|---|---|---|---|---|---|---|
| | | | | | កសិដ្ឋាន | | ចំនួនសត្វ (ក្បាល) | |
| | កសិដ្ឋាន | សត្វ(ក្បាល) | កសិដ្ឋាន | សត្វ (ក្បាល) | កើន/ថយ | (%) | កើន/ថយ | (%) |
| គោ ក្របី | 86 | 13.289 | 93 | 23.382 | 7 | 8,14 | 10.093 | 75,95 |
| ជ្រូក | 491 | 416.525 | 575 | 599.341 | 84 | 17,11 | 182.816 | 43,89 |
| បក្សី | 2.276 | 2.830.398 | 1.630 | 7.331.275 | -646 | -28,38 | -499.123 | -6,37 |
| សរុប | 2.853 | 8.260.212 | 2.298 | 7.953.998 | -555 | -19,45 | -306.214 | -3,07 |

## ២.៣ សរុបផលិតកម្មជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្ម

តារាងខាងក្រោមបង្ហាញពីវឌ្ឍនភាពនៃការចិញ្ចឹមសត្វសរុបទាំងលក្ខណៈគ្រួសារ និងលក្ខណៈពាណិជ្ជកម្ម ទូទាំងប្រទេសរយៈពេលប្រាំឆ្នាំ ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៦។ តួលេខក្នុងតារាងនេះបានឲ្យដឹងថា ចំនួនសត្វចិញ្ចឹមសរុបបានកើនជាលំដាប់ជារៀងរាល់ឆ្នាំ ពី២៩.៦១៧.៣៥៤ ក្បាលនៅឆ្នាំ២០១២ ដល់ ៤២.១៨៣.៣៩៤ ក្បាល នៅឆ្នាំ២០១៦។ ក្នុងរយៈពេល៥ឆ្នាំនេះកើន១២.៥៦៦.០៤០ ក្បាល ស្មើនឹង ៤២%។ ដោយឡែកបើធៀបឆ្នាំ២០១៥ និង២០១៦ កើន១.៤៣០.០០០ ក្បាល ស្មើនឹង ៣,៥១%។ កំណើននេះលើសពីផែនការដែលបានកំណត់៣ %ក្នុងមួយឆ្នាំ។

**តារាងស្ថិតិសត្វចិញ្ចឹមសរុបទាំងលក្ខណៈគ្រួសារ និងលក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០១២-២០១៦**

| ល.រ | ប្រភេទ | | ស្ថិតិសត្វប្រាំឆ្នាំចុងក្រោយ (២០១២-២០១៦) | | | | | ប្រៀបធៀប |
|---|---|---|---|---|---|---|---|---|
| | ផលិតកម្ម | សត្វ | 2012 | 2013 | 2014 | 2015 | 2016 | 2015&2016 |
| A | B | C | 1 | 2 | 3 | 4 | 5 | 6=5/4 |
| 1 | លក្ខណៈគ្រួសារ | គោ | 3.372.212 | 3.425.952 | 3.053.481 | 2.903.420 | 2.897.126 | -0,22% |
| 2 | | ក្របី | 656.938 | 619.114 | 541.827 | 506.165 | 523.320 | 3,39% |
| 3 | | ជ្រូក | 1.952.321 | 2.067.975 | 2.360.823 | 2.357.839 | 2.371.283 | 0,57% |
| 4 | | បក្សី | 19.374.139 | 21.429.519 | 25.630.027 | 26.688.675 | 28.402.486 | 6,42% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 5 | | សេះ | 12.394 | 10.850 | 9.161 | 7.637 | 5.610 | -26,54% |
| 6 | | ចៀម | 174 | 100 | 238 | 378 | 400 | 5,82% |
| 7 | | ពពែ | 11.995 | 15.831 | 18.256 | 23.321 | 22.719 | -2,58% |
| 8 | | ដំរី | 64 | 64 | 63 | 64 | 63 | -1,56% |
| សរុប | | | 25.380.237 | 27.569.405 | 31.613.876 | 32.487.499 | 34.223.007 | 5,34 |
| 1 | លក្ខណៈពាណិជ្ជកម្ម | គោ | 4.593 | 4.882 | 6.446 | 13.289 | 23.188 | 74,49% |
| 2 | | ក្របី | 37 | 52 | 32 | 63 | 194 | 207,94% |
| 3 | | ជ្រូក | 256.290 | 370.204 | 374.894 | 416.525 | 599.341 | 43,89% |
| 4 | | បក្សី | 3.974.291 | 6.194.898 | 5.953.630 | 7.830.398 | 7.331.275 | -6,37% |
| 5 | | សេះ | 137 | 47 | 47 | 41 | 64 | 56,10% |
| 6 | | ចៀម | 41 | 15 | 15 | 31 | 67 | 116,13% |
| 7 | | ពពែ | 1.728 | 5.187 | 4.988 | 5.547 | 6.258 | 12,82% |
| សរុប | | | 4.237.117 | 6.575.285 | 6.340.052 | 8.265.894 | 7.960.387 | -3,70% |
| **សរុបរួម** | | | 29.617.354 | 34.144.690 | 37.953.928 | 40.753.393 | 42.183.394 | 3,51% |

## ក្រាហ្វិកប្រៀបធៀបស្ថិតិសត្វចិញ្ចឹមសរុបពីឆ្នាំ២០១២-២០១៦




## ក្រាហ្វិកការប្រៀបធៀបស្ថិតិគោ ក្របីប្រើប្រាស់ជាកម្លាំងអូសទាញពីឆ្នាំ ២០១២-២០១៦



## ២.៤. ការប្រៀបធៀបបែបផែនផលិតកម្មតាមប្រភេទសត្វ

តារាងខាងក្រោមបង្ហាញការប្រែប្រួលបែបផែនផលិតកម្មតាមប្រភេទសត្វ ក្នុងរយៈពេល៥ ឆ្នាំ។ តាមតួលេខនៃតារាងនេះបានបង្ហាញថា៖

–ការចិញ្ចឹមគោ ក្របី៖ ការចិញ្ចឹមគោ ក្របីជាលក្ខណពាណិជ្ជកម្មមានការកើនឡើងជាលំដាប់ ប៉ុន្តែការចិញ្ចឹមជាលក្ខណៈគ្រួសារមានការថយចុះ ប្រមាណ១៤,៦២ភាគរយ ក្នុងអំឡុងពេល៥ ឆ្នាំ។ ការថយចុះនៃការចិញ្ចឹមជាលក្ខណៈគ្រួសារនេះគឺបណ្តាលមកបីការថយចុះវាលស្មៅ ទឹកសម្រាប់គោ-ក្របី ការថយចុះកម្លាំងអ្នកឃ្វាលគោ-ក្របី និងការកើនឡើងនូវគ្រឿងយន្តកសិកម្ម។ ដោយឡែកនៅឆ្នាំ២០១៦ មានការកើនឡើងវិញបើធៀបទៅនឹងឆ្នាំ២០១៥។ កំណើននេះបានមកពីការកើនឡើងនៃការចិញ្ចឹមគោ-ក្របី ជាលក្ខណៈពាណិជ្ជកម្ម និងក្របីជាលក្ខណៈគ្រួសារ កើនប្រមាណជា០,៦១ %។ បើប្រៀបធៀបបែបផែនផលិតកម្មឃើញថាការចិញ្ចឹមគោ ក្របីជាលក្ខណៈពាណិជ្ជកម្មមានការកើនឡើង។

–ការចិញ្ចឹមជ្រូក៖ការចិញ្ចឹមជ្រូកមានការកើនឡើងជាលំដាប់ទាំងការចិញ្ចឹមជា លក្ខណៈគ្រួសារ និងពាណិជ្ជកម្មសរុបក្នុងអំឡុងពេល៥ ឆ្នាំ នេះកើន៣៤,៥ ភាគរយ ក្នុងនោះការចិញ្ចឹមជាលក្ខណៈគ្រួសារកើន២១,៥% និងលក្ខណៈពាណិជ្ជកម្មកើន១៣៤%។ ដោយឡែកនៅឆ្នាំ២០១៦ មានការកើនឡើងចំនួន៧,០៧% បើធៀបទៅនឹងឆ្នាំ២០១៥។ កំណើននេះបានមកពីការកើនឡើងនៃការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មចំនួន៤៣,៨៩% ចំពោះការចិញ្ចឹមជាលក្ខណៈគ្រួសារកើន០,៥៧%។ បើប្រៀបធៀបបែបផែនផលិតកម្មឃើញថាការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មមានចំនួន២០% កើនឡើងប្រមាណ៥% ធៀបទៅនឹងឆ្នាំ២០១៥។

–ការចិញ្ចឹមបក្សី៖ការចិញ្ចឹមបក្សីមានការកើនឡើងជាលំដាប់ ទាំងការចិញ្ចឹមជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្មសរុបក្នុងអំឡុងពេល៥ ឆ្នាំនេះកើន៥៣,០៣% ក្នុងនោះការចិញ្ចឹមជាលក្ខណៈគ្រួសារកើន៤៦,៦% និងលក្ខណៈពាណិជ្ជកម្មកើន៨៤,៤៧%។ ដោយឡែកនៅឆ្នាំ២០១៦ កើនត្រឹមតែ៣,៥៧%បើធៀបទៅនឹងឆ្នាំ២០១៥។ កំណើននេះបានមកពីការកើនឡើងនៃការចិញ្ចឹមមាន់ស្រុកជាលក្ខណៈគ្រួសារ កើនប្រមាណ៦,៤២% និងចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មមានការថយចុះប្រមាណ៦,៣៧%។ បើប្រៀបធៀបបែបផែនផលិតកម្មឃើញថាការចិញ្ចឹមបក្សីជាលក្ខណៈពាណិជ្ជកម្មមានចំនួន២១%ឆ្នាំ២០១៦បានថយចុះ១%។ ការថយចុះនេះ បណ្តាលមកពីមានការប្រកួតប្រជែងបក្សីនាំចូលដែលមានតម្លៃទាបជាង និងការប្រកួតប្រជែងពីបក្សីចិញ្ចឹមជាលក្ខណៈគ្រួសារដែលមានការនិយមជាង ទោះបីជាមានតម្លៃខ្ពស់ ក៏រក្សាបាននូវតម្រូវការទីផ្សារ។ (ឧបសម្ព័ន្ធទី៤និងទី៥)

**តារាងប្រៀបធៀបស្ថិតិគោ ក្របី ជ្រូកនិងបក្សីចិញ្ចឹមតាមបែបផែនផលិតកម្មពីឆ្នាំ២០១២-២០១៦**

| ប្រភេទ | | ឆ្នាំ | | | | | ប្រៀបធៀប |
|---|---|---|---|---|---|---|---|
| សត្វ | លក្ខណៈ | 2012 | 2013 | 2014 | 2015 | 2016 | 2015និង2016 |
| គោ ក្របី | គ្រួសារ | 4.029.150 | 4.045.066 | 3.595.308 | 3.409.585 | 3.420.446 | 0,32 |
| | ពាណិជ្ជកម្ម | 4.630 | 4.934 | 6.478 | 13.352 | 23.382 | 75,12 |
| | **សរុប** | 4.033.780 | 4.050.000 | 3.601.786 | 3.422.937 | 3.443.828 | 0,61 |
| ជ្រូក | គ្រួសារ | 1.952.321 | 2.067.875 | 2.360.823 | 2.357.839 | 2.371.283 | 0,57 |
| | ពាណិជ្ជកម្ម | 256.290 | 370.204 | 374.894 | 416.525 | 599.341 | 43,89 |
| | **សរុប** | 2.208,611 | 2.438.079 | 2.735.717 | 2.774.364 | 2.970.624 | 7,07 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| បក្សី | គ្រួសារ | 19.374.139 | 21.429.519 | 25.630.027 | 26.688.675 | 28.402.486 | 6,42 |
| | ពាណិជ្ជកម្ម | 3.974.291 | 6.194.898 | 5.953.630 | 7.830.398 | 7.331.275 | -6,37 |
| | **សរុប** | 23.348.430 | 27.624.417 | 31.583.657 | 34.519.073 | 35.733.761 | 3,52 |

## ក្រាហ្វិកប្រៀបធៀបស្ថិតិ គោ និងក្របីពីឆ្នាំ២០១២-២០១៦




## ក្រាហ្វិកប្រៀបធៀបស្ថិតិជ្រូកពីឆ្នាំ ២០១២-២០១៦




## ក្រាហ្វិកប្រៀបធៀបស្ថិតិបក្សីពីឆ្នាំ ២០១២-២០១៦



### ក្រាហ្វិកប្រៀបធៀបបែបផែនផលិតកម្មជ្រូក និងបក្សីពីឆ្នាំ២០១៥-២០១៦




### ក្រាហ្វិកប្រៀបធៀបបែបផែនផលិតកម្មជ្រូក និងបក្សីពីឆ្នាំ២០១៥-២០១៦




## ២.៥.តម្រូវការសត្វ និងសាច់ឆ្នាំ ២០១៦

**តម្រូវការ៖** ការអភិវឌ្ឍទីក្រុង កំណើនសេដ្ឋកិច្ច ការផ្លាស់ប្តូររបៀបរបបនៃការបរិភោគអាហាររបស់ប្រជាពលរដ្ឋកម្ពុជាកំណើនប្រជាជននិងកំណើននៃប្រាក់ចំណូលជាមធ្យម បានជំរុញតម្រូវការសត្វ សាច់ និង ផលិតផលសត្វ មានការកើនឡើងជាលំដាប់។

### ក្រាហ្វិកប៉ាន់ស្មានកំណើនប្រជាជនកម្ពុជាពីឆ្នាំ ២០០០-២០៣០



មានទិន្ន័យជាច្រើនខុសៗគ្នាអំពីតម្រូវការ និងការផ្គត់ផ្គង់សាច់នៅកម្ពុជា។ ប៉ុន្តែតាមក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វឆ្នាំ២០១៦-២០២៥ ដែលទើបនឹងដាក់ឲ្យអនុវត្តនៅឆ្នាំ២០១៦ នេះ បានឲ្យដឹងថា ប្រជាជនកម្ពុជា ម្នាក់ជាមធ្យមក្នុងមួយឆ្នាំ បរិភោគសាច់ ១៦.១៣ គីឡូក្រាម។ ផ្អែកលើទិន្នន័យនេះ យើងអាចព្យាករណ៍តម្រូវការសាច់នៅឆ្នាំ២០១៦ នេះ មានចំនួសរុប២៨៩.០៩១ តោន ក្នុងនោះសាច់គោ ៨១.២០៤ តោន សាច់ជ្រូក១៨៣.៤៩៧ តោន និងសាច់បក្សី២៤.២១៣ តោន បើគិតជាក្បាល គោប្រមាណ ៦៧៦.៧០១ ក្បាល និងជ្រូក៣.៦៦៩.៩៤៩ ក្បាល។

**ក្រាហ្វិកព្យាករណ៍តម្រូវការសាច់ពីឆ្នាំ ២០១៤-២០២៤**




**ការផ្គត់ផ្គង់៖** តាមរបាយការណ៍ពិឃាតសត្វទូទាំងប្រទេសនាឆ្នាំ២០១៦ នេះ រួមទាំងសត្វនាំចូលផងនោះមានចំនួន៖

១. គោ និងក្របីចំនួន១២៨.៩០៤ ក្បាល

២.ជ្រូកចំនួន៨៩៤.១០៨ ក្បាល។ ចំនួននេះតិចជាងចំនួនដែលបានព្យាករណ៍ប្រចាំឆ្នាំ ២០១៦។

**ក្រាហ្វិកប្រៀបធៀបស្ថិតិសត្វពិឃាតដែលបានរាយការណ៍ពីឆ្នាំ២០១២-២០១៦**



**ការបំពេញបន្ថែម៖** ដោយសារផលិតកម្មសត្វក្នុងស្រុកមិនគ្រប់គ្រាន់តាមតម្រូវការ ដូចនេះនៅឆ្នាំ២០១៦ មានការនាំចូលសត្វរស់ និងផលិតសត្វ ដើម្បីបំពេញបន្ថែមសម្រាប់ទីផ្សារទំនើប សណ្ឋាគារ និងភោជនីយដ្ឋាននានា ដែលបរិមាណនាំចូលរួមមាន៖

១. ជ្រូករស់ចំនួន៤៥៩.១៧៥ ក្បាល

២. មាន់៣.៧២២.៤២០ ក្បាល

៣. សាច់គោ សាច់ក្របី សាច់ជ្រូក សាច់មាន់ សាច់ទា និងសាច់ក្រួច ៨២៧.៣៧៤ គីឡូក្រាម

៤.ប្រហិត និងប្រូម៉ាស់ចំនួន៥៨.៤៤២ គីឡូក្រាម។

**តារាងស្ថិតិនាំចូលសត្វរស់ពីឆ្នាំ២០១៤ដល់ឆ្នាំ ២០១៦**

| សត្វពិឃាត | 2014 | 2015 | 2016 | ប្រៀបធៀបឆ្នាំ |
|---|---|---|---|---|
| | | | | 2015 និង 2016 |
| ជ្រូកសាច់រស់ (ក្បាល) | 449.480 | 493.600 | 459.175 | -6.97 |
| មាន់ និងទារស់(ក្បាល) | 666.300 | 1.451.750 | 3.722.420 | 156,41 |
| ពពែ និងចៀម (ក្បាល) | 140 | 780 | | |

**ក្រាហ្វិកប្រៀបធៀបស្ថិតិសត្វនាំចូលពីឆ្នាំ២០១៤-២០១៦**






ក្រាហ្វិកប្រៀបធៀបស្ថិតិផលិតផលសត្វនាំចូលពីឆ្នាំ២០១៤-២០១៦




ក្រាហ្វិកខាងលើបានបង្ហាញថាការនាំចូលមាន់រស់នាឆ្នាំ២០១៦ មានការកើនឡើង២.៣០០.០០០ក្បាល ស្មើនឹង៥៦% ធៀបទៅនឹងឆ្នាំ២០១៥។ ដោយឡែកការនាំចូលជ្រូក និងសាច់សត្វគ្រប់ប្រភេទ ថយចុះ ជាងឆ្នាំ២០១៥ ប្រមាណ៧ % ប៉ុន្តែផលិតផលសត្វ និងផលិតផលកែច្នៃបានកើន ឡើងខ្លាំងបើធៀប នឹងឆ្នាំ ២០១៥ ។

## ២.៦កម្មវិធីកែលម្អពូជ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បាន និងកំពុងជំរុញ អនុវត្តកម្មវិធី កែលម្អពូជ សត្វដែលជាពូជសត្វផ្តល់ផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ព្រមទាំងធន់នឹងបរិស្ថាននៅកម្ពុជា។ ការកែលម្អពូជប្រព្រឹត្តទៅទាំងការជ្រើសរើសមេបាល្អៗ យកមកបង្កាត់តាមរយៈការបង្កាត់ដោយសិប្បនិម្មិត ការនាំចូលមេជីវិត និងពូជសត្វល្អៗពីបរទេស បង្កាត់ជាមួយពូជក្នុងស្រុកដែលមាន លក្ខណៈបន្សាំទៅ នឹងអាកាសធាតុល្អ។

***ការកែលម្អពូជគោ៖*** បាននាំចូលពូជគោ និងមេជីវិតគោមកបង្កាត់សិប្បនិម្មិតជាមួយពូជគោក្នុងស្រុក។ បច្ចុប្បន្នកម្មវិធីនេះបាននិងកំពុងអនុវត្តខេត្តពោធិ៍សាត់ កំពង់ស្ពឺ ខេត្តតាកែវ និងខេត្តត្បូងឃ្មុំ។ លទ្ធផលនៃការបង្កាត់ក្នុងឆ្នាំ២០១៦ បង្កាត់សិប្បនិម្មិតគោសរុប៤៩៣ ក្បាល។

ក្រៅពីនេះ មានកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសបង្កាត់សិប្បនិម្មិត្តគោ កម្មវិធីតាមដាន និងផ្សព្វផ្សាយបច្ចេកទេស និងផលប្រយោជន៍នៃការបង្កាត់សិប្បនិម្មិតគោដល់មន្ត្រី២៥ រាជធានី-ខេត្ត។ អគ្គនាយកដ្ឋានបានរៀបចំកម្មវិធីតាមដាន និងអនុវត្តជាក់ស្តែង ជាមួយនឹងការផ្សព្វផ្សាយអំពីផលប្រយោជន៍នៃការបង្កាត់សិប្ប-និម្មិតគោ ដល់កសិករចិញ្ចឹមសត្វ អាជ្ញាធរមូលដ្ឋាន ថ្នាក់ដឹកនាំមន្ទីរកសិកម្ម និងមន្ត្រីជំនាញតាមបណ្តារាជធានី-ខេត្ត។ បានជ្រើសរើសគោបាពូជល្អៗ ក្នុងស្រុក ប្រមូលមេជីវិត បង្កក សម្រាប់បង្កាត់ពូជបែបសិប្បនិម្មិតជាមួយមេគោពូជក្នុងស្រុក។ នៅឆ្នាំ២០១៦ នេះ ផលិតទឹកមេជីវិតបានចំនួន៣៥០បំពង់ ព្រមទាំងបានប្រើប្រាស់មេជីវិតដែលផលិតនេះបង្កាត់បាន១១៦ ក្បាល។ កម្មវិធីក៏បានភ្ជាប់ជាមួយនូវការអនុវត្តជាក់ស្តែងដល់មន្ត្រី

ថ្នាក់រាជធានី-ខេត្ត និងស្រុកមួយចំនួន ដើម្បីផ្ទេរចំណេះដឹង និងបទពិសោធន៍លើការបង្កាត់សិប្បនិម្មិតនេះដល់អ្នកអនុវត្តជាក់ស្តែង។

***ការកែលម្អពូជជ្រូក៖*** បានកែលម្អពូជជ្រូកតាមរយៈការនាំចូលពូជជ្រូកបាល្អពីបរទេស។ ពូជទាំងនេះបានថែរក្សានៅមជ្ឈមណ្ឌលបង្កាត់ពូជជ្រូកសិប្បនិម្មិតនៅខេត្តកំពង់ឆ្នាំង តាកែវ កំពង់ស្ពឺ បាត់ដំបង សៀមរាប កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង និងខេត្តស្វាយរៀង។ បច្ចុប្បន្នមជ្ឈមណ្ឌលបង្កាត់ពូជទាំងនោះ បាននិងកំពុងដំណើរការផលិតមេជីវិត និងបង្កាត់បែបសិប្បនិម្មិតជូនកសិករចិញ្ចឹមសត្វខ្នាតតូច។ សរុបក្នុងឆ្នាំ២០១៦ បង្កាត់បាន ១.០១៩ ក្បាល។

ក្នុងផ្នែកនេះដែរ បានបង្កើនសមត្ថភាពមន្ត្រីតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសបង្កាត់សិប្បនិម្មិតជ្រូកដល់មន្ត្រី២៥ រាជធានី-ខេត្តព្រមទាំងបានរៀបចំកម្មវិធីតាមដាន ផ្សព្វផ្សាយបច្ចេកទេស និងផលប្រយោជន៍នៃការបង្កាត់សិប្បនិម្មិតជ្រូក និងអនុវត្តជាក់ស្តែងនៅតាមបណ្តារាជធានី-ខេត្តមួយចំនួន ដើម្បីធានាថាមន្ត្រីបច្ចេកទេសដែលបានចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនេះមានបទពិសោធន៍ និងចំណេះដឹងអាចអនុវត្តបាន។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានផលិត និងលក់ចែកចាយកូនជ្រូកពូជនាំចូលពីសាធារណៈរដ្ឋប្រជាមានិតចិន ដែលជាពូជមានគុណភាពល្អ ស៊ីចំណីតិច តែលូតលាស់លឿន និងមានសាច់ក្រហមច្រើន។ សរុបនៅឆ្នាំ២០១៦ នេះ បានលក់ជូនកសិករចិញ្ចឹមសត្វខ្នាតតូច និងសហគមន៍នៅតាមបណ្តារាជធានី-ខេត្តចំនួន០៧ រួមមាន ខេត្តកំពង់ស្ពឺ កំពង់ចាម ត្បូងឃ្មុំ តាកែវ ស្វាយរៀង ព្រៃវែង និងខេត្តកណ្តាល សរុបចំនួន៦៣៩ក្បាល។

## ២.៧.ចំណីសត្វ

**ចំណីសត្វនិងការប្រើប្រាស់៖** ថ្វីបើប្រទេសកម្ពុជាជាប្រទេសដែលសម្បូរទៅដោយវត្ថុធាតុដើមសម្រាប់ផលិតចំណីសត្វដូចជាពោត ដំឡូងមី សណ្តែក កន្ទក់ ចុងអង្ករកូនត្រី និងឆ្អឹងសត្វជាដើម ប៉ុន្តែវត្ថុធាតុដើមមួយចំនួនធំ ត្រូវបានលក់ចេញទៅប្រទេសវៀតណាម និងប្រទេសថៃឡង់ដ៏ ហើយនាំចូលមកវិញនូវចំណីសម្រេច។

ប៉ុន្តែស្ថានភាពខាងលើបានប្រែប្រួលបន្តិចម្តងៗ ដោយនាពេលប៉ុន្មានឆ្នាំចុងក្រោយ គេក៏ឃើញមានការវិនិយោគលើការសាងសង់រោងចក្រផលិតចំណីសត្វជាបន្តបន្ទាប់។ បច្ចុប្បន្នមានរោងចក្រចំនួន១៣ ដែលបាននិងកំពុងផលិត និងលក់ចែកចាយចំណីសត្វក្នុងស្រុក។ អាស្រ័យហេតុនេះ ការនាំចូលចំណីមានការថយចុះចាប់ពីឆ្នាំ២០១៥។

**ក្រាហ្វិកប្រៀបធៀបតម្រូវការនាំចូលចំណីសត្វ និងចំណីបន្ថែមពីឆ្នាំ ២០១២-២០១៥**



**វិធានការសម្រាប់ដោះស្រាយបញ្ហាកង្វះចំណីសត្វ**

ការធ្វើពិពិធកម្មនិងការបង្កើនផ្ទៃដីដាំដុះដំណាំ គ្រោះធម្មជាតិទាំងរាំងស្ងួត ទាំងទឹកជំនន់ បានបង្ករផលប៉ះពាល់ដល់វាលស្មៅធម្មជាតិសម្រាប់ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ។ ដើម្បីជំនះនូវឧបសគ្គនេះអង្គភាពជំនាញបាននាំចូលនូវពូជស្មៅល្អៗពីបរទេស ដែលមានទិន្នផលខ្ពស់ សមស្របនឹងអាកាសធាតុកម្ពុជា។ ពូជស្មៅទាំងនោះ បានត្រូវផ្សព្វផ្សាយតាមរយៈការធ្វើបង្ហាញពីបច្ចេកទេសដាំ និងប្រើប្រាស់នៅទូទាំង២៥រាជធានី-ខេត្ត។

ម្យ៉ាងវិញទៀត អគ្គនាយកដ្ឋានបានបណ្តុះបណ្តាលបច្ចេកទេសផលិតលាយផ្សំចំណីគោ ជ្រូក មាន់ និងទា ពីវត្ថុធាតុដើមដែលអាចរកបានក្នុងមូលដ្ឋាន ដល់កសិករក្នុងខេត្តគោលដៅមួយចំនួន ក្នុងនោះមានខេត្តបន្ទាយមានជ័យ កំពត ក្រចេះ ព្រះសីហនុ ព្រះវិហារ រតនៈគិរី សៀមរាប ត្បូងឃ្មុំ និងខេត្តឧត្តរមានជ័យ ដែលមានកសិករចូលរួមចំនួន៤៣៦នាក់ ក្នុងនោះមានស្ត្រី១៦៦នាក់។

***ការគ្រប់គ្រងគុណភាព សុវត្ថិភាពចំណីសត្វដែលចរាចរលើទីផ្សារ៖*** អង្គភាពជំនាញក៏មានទួនាទីត្រួតពិនិត្យការធ្វើអាជីវកម្មចំណីសត្វ ដើម្បីធានាថា ចំណីសត្វដែលបានចុះបញ្ជីឲ្យចរាចរលើទីផ្សារក្នុងស្រុក និងនាំចេញ ពិតជាមានគុណភាព ស្របតាមស្តង់ដារ និងសុវត្ថិភាព គ្មានសារធាតុពុល បង្ករផលប៉ះពាល់ដល់សុខភាពសត្វ និងសុខភាពមនុស្ស។ ដោយបានត្រួតពិនិត្យ វិភាគ ផ្ទៀងផ្ទាត់គុណភាព មុនពេលអនុញ្ញាតចុះបញ្ជីនាំចេញនិងនាំចូល។ អង្គភាពក៏បានបំពាក់ម៉ាស៊ីនវិភាគចំណីសត្វនៅមន្ទីរពិសោធន៍វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ ដែលនឹងដាក់ឲ្យដំណើរការនាពេលខ្លីខាងមុខ។

***ស្ថានភាពតម្លៃសត្វ សាច់ និងផលិតផលសត្វ៖*** បញ្ហាធំមួយដែលតែងតែជួបប្រទះ គឺនៅពេលតម្លៃសត្វរស់ចុះថោក ហើយដែលកសិកសង្ឃឹមថាអង្គភាពជំនាញមានសមត្ថភាពដោះស្រាយ។ ឆ្លើយតបនឹងក្តីសង្ឃឹមនេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានតាមដានពីស្ថានភាពនៃការប្រែប្រួលតម្លៃជាប្រចាំតាមរយៈការចុះអង្កេត និងរបាយការណ៍ពីការិយ័យផលិតកម្ម និងបសុព្យាបាលរាជធានី-ខេត្តតាមលទ្ធផលនៃការស្រាវជ្រាវនេះ បានឲ្យដឹងថា តម្លៃសត្វរស់ សាច់ និងផលិតផលសត្វ មានការកើនឡើងស្របគ្នាជាលំដាប់រហូតដល់ឆ្នាំ២០១៤ តែនៅឆ្នាំ២០១៥ បានធ្លាក់ចុះមកវិញ និងបន្តធ្លាក់ចុះដល់ឆ្នាំ២០១៦។ ទោះបីជាមានការធ្លាក់ចុះតម្លៃសត្វរស់នៅឆ្នាំ២០១៦ ក៏ដោយក៏ជារួមតម្លៃនេះខ្ពស់ជាងតម្លៃសត្វរស់នាឆ្នាំ២០១២ និងថ្លៃជាងតម្លៃជ្រូករស់ និងបក្សីនៅប្រទេសជិតខាងនាពេលបច្ចុប្បន្ន។

## ក្រាហ្វិកប្រៀបធៀបតម្លៃសត្វរស់ពីឆ្នាំ២០១២-២០១៦




## ក្រាហ្វិកប្រៀបធៀបតម្លៃជ្រូករស់ និងសាច់ជ្រូកពីឆ្នាំ ២០១២-២០១៦




## ក្រាហ្វិកប្រៀបធៀបតម្លៃគោរស់ និងសាច់គោពីឆ្នាំ២០១២-២០១៦



ក្រាហ្វិកប្រៀបធៀបតម្លៃសត្វរស់ និងសាច់ ខាងលើបានឲ្យដឹងថាតម្លៃសាច់ជ្រូកលើទីផ្សារមានការកើនឡើង ប៉ុន្តែជ្រូករស់បែរជាចុះថ្លៃទៅវិញ។ បញ្ហានេះបានប៉ះពាល់យ៉ាងខ្លាំងដល់កសិករចិញ្ចឹមសត្វខ្នាតតូច ដែលជាទូទៅថ្លៃដើមក្នុងការផលិតរបស់ពួកគាត់ខ្ពស់ បើធៀបនឹងការចិញ្ចឹមបែបឧស្សាហកម្ម។ ចំណែកឯគោវិញ ក៏មានភាពខុសគ្នាខ្លាំងរវាងសត្វរស់ និងសាច់ ដោយពិនិត្យឃើញថាគោរស់ចុះថ្លៃ ឯសាច់គោបែរជាឡើងថ្លៃទៅវិញ។

## ២.៨ ការគ្រប់គ្រងកាកសំណល់សត្វ

ជាការពិតការចិញ្ចឹមសត្វមានតួនាទីយ៉ាងសំខាន់ ប៉ុន្តែទន្ទឹមនឹងនេះ នៅពេលដែលផលិតកម្មសត្វកាន់តែត្រូវបានគេអភិវឌ្ឍន៍វានឹងមានផលប៉ះពាល់អវិជ្ជមានចំពោះបរិស្ថាន ដោយសារតែមានការបំភាយឧស្ម័នផ្ទះកញ្ចក់ដូចជាឧស្ម័ន $CH_4$, $CO_2$, $N_2O$និងឧស្ម័នផ្សេងៗ ទៀត ។

ដើម្បីទប់ស្កាត់ផលប៉ះពាល់ដែលកើតឡើងពីការអភិវឌ្ឍវិស័យនេះ អង្គភាពបានយកចិត្តទុកដាក់លើការជំរុញការគ្រប់គ្រងកាកសំណល់សត្វនៅតាមកន្លែងអាជីវកម្មសត្វ និងផលិតផលសត្វ។ ដូចជានៅកសិដ្ឋានចិញ្ចឹមសត្វ កន្លែងចិញ្ចឹម សត្តឃាតដ្ឋាន។ល។ ក្រៅពីនេះក៏បានណែនាំ និងតម្រូវឲ្យកសិដ្ឋានធំៗធ្វើអាងប្រព្រឹត្តកម្មសត្វកាកសំណល់សត្វ សាងសង់ឡជីវឧស្ម័នខ្នាតធំ និងខ្នាតតូចសម្រាប់គ្រប់គ្រងកាកសំណល់សត្វតាមកសិកដ្ឋាន និងតាមគ្រួសារ។ ក្នុងគោលបំណងមិនត្រឹមតែគ្រប់គ្រងកាកសំណល់សត្វ តែអាចកាត់បន្ថយផលប៉ះពាល់ពីការបំភាយឧស្ម័នផ្ទះកញ្ចក់ ដែលវានឹងមានផលប៉ះពាល់អវិជ្ជមានចំពោះបរិស្ថាន។ ដោយនៅឆ្នាំ២០១៦ នេះ បានសាងសង់ឡជីវឧស្ម័នជាលក្ខណៈគ្រួសារបានសរុបចំនួន ១.៤៣៣ឡក្នុងខេត្តចំនួន១២ រួមមាន ខេត្តកំពង់ចាម ត្បូងឃ្មុំ ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្ដាល កំពង់ឆ្នាំង កំពតសៀមរាប កំពង់ធំ និងខេត្តពោធិ៍សាត់។

# ៣-ការលើកកម្ពស់សុខភាពសត្វ និងសុខភាពសាធារណៈ

ចក្ខុវិស័យនៃការអភិវឌ្ឍវិស័យនេះ គឺ ពង្រឹងសេវាសុខភាពសត្វ និងផលិតកម្មសត្វ ដែលនឹងកាត់បន្ថយផលប៉ះពាល់នៃជំងឺសត្វ បង្កើនផលិតភាពសត្វ និងលើកកម្ពស់ការធ្វើពាណិជ្ជកម្មសត្វប្រកបដោយសុវត្ថិភាព។ ដើម្បីគាំទ្រដល់ការសម្រេចបាននូវចក្ខុវិស័យខាងលើសកម្មភាពគាំទ្រសំខាន់ៗ នៅក្នុងផ្នែកនេះ រួមមាន៖ ការពង្រឹងសុខភាពសត្វ ដែលផ្ដោតសំខាន់លើការត្រួតពិនិត្យអនាម័យ គុណភាព សុវត្ថិភាព ការពង្រឹងការផ្ដល់សេវាកម្មបសុព្យាបាល ដើម្បីកាត់បន្ថយការឆ្លងរាលដាលជំងឺសត្វ និងការពង្រឹងការផ្គត់ផ្គង់សាច់សត្វប្រកបដោយគុណភាពនៅលើទីផ្សារ ដើម្បីការពារសុខភាពសាធារណៈ។

## ៣.១ ការការពារសុខភាពសត្វ

### ក- ការឆ្លើយតបនឹងការផ្ទុះជំងឺឆ្លងសត្វ

នៅឆ្នាំ២០១៦ នេះ ស្ថានភាពជំងឺឆ្លងសត្វត្រូវបានរាយការណ៍ចំនួន២១២ ករណី ក្នុងនោះជំងឺដែលផ្ទុះច្រើនជាងគេគឺជំងឺអុតក្ដាមគោ ក្របី។ ឆ្នាំនេះ ថ្វីបើមានការផ្ទុះជំងឺសត្វច្រើនក៏ពិតមែន ប៉ុន្តែអាស្រ័យដោយមានការត្រៀមលក្ខណៈបានល្អ ជំងឺឆ្លងទាំងនេះ បានត្រូវទប់ស្កាត់ ដោយមិនបណ្ដោយឲ្យឆ្លងរាលដាលធ្ងន់ធ្ងរទៅតំបន់ជិតខាង។ ចំណែកជំងឺស៊ូល្វសឆ្នាំនេះ មានផ្ទុះតែមួយករណី។( ឧបសម្ព័ន្ធទី ៦ និងទី៧ )

**តារាងប្រៀបធៀបស្ថានភាពជំងឺឆ្លងសត្វពីឆ្នាំ ២០១២-២០១៦**

| ជំងឺសត្វឆ្លងសំខាន់ៗ | 2012 | 2013 | 2014 | 2015 | 2016 |
|---|---|---|---|---|---|
| អុតក្ដាមគោក្របី | 22 | 72 | 60 | 45 | 100 |

| | | | | | |
|---|---|---|---|---|---|
| សាទឹកគោ ក្របី | 44 | 27 | 39 | 66 | 45 |
| បូសខ្យល់គោ ក្របី | 1 | 4 | 0 | 12 | 28 |
| ប៉េស្តជ្រូក | 30 | 7 | 24 | 45 | 37 |
| ត្រចៀកខៀវជ្រូក | 0 | 0 | 0 | 9 | 1 |
| ផ្តាសាយបក្សី | 1 | 7 | 5 | 2 | 1 |

**ក្រាហ្វិកក្រាហ្វិកបង្ហាញពីស្ថានភាពជំងឺឆ្លងសំខាន់ៗ លើគោ ក្របីឆ្នាំ២០១២-២០១៦**




## ខ-ការផ្តល់សេវាកម្មសុខភាពសត្វដល់អ្នកចិញ្ចឹមសត្វខ្នាតតូច

ទិសដៅកម្ពុជាគឺជំរុញផលិតកម្មសត្វពីទ្រង់ទ្រាយតូចទៅជាលក្ខណៈឧស្សាហកម្ម ប៉ុន្តែក៏នៅតែបន្តគាំទ្រការចិញ្ចឹមសត្វខ្នាតតូច ដែលមានបរិមាណជាង៨០%។ ផលិតកម្មសត្វខ្នាតតូចនេះ បាន និងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងបង្កើនចំណូលជនបទ។ ការគាំទ្រដល់អ្នកចិញ្ចឹមសត្វខ្នាតតូច នេះ បានធ្វើឡើងតាមរយៈការផ្តល់សេវាកម្មបសុពេទ្យាបាល ការចាក់វ៉ាក់សាំងការពារ ការផ្សព្វផ្សាយ និងធ្វើជីវៈសុវត្ថិភាព ព្រមទាំងអន្តរាគមន៍ករណីមានផ្ទុះជំងឺសត្វ។ នាឆ្នាំ២០១៦ នេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ សហការជាមួយមន្ត្រីការិយាល័យផលិតកម្ម និងបសុពេទ្យាបាលរាជធានី-ខេត្តនិងមានការចូលរួមគាំទ្រពីអាជ្ញាធរមូលដ្ឋាន និងកិច្ចសហការរបស់ភ្នាក់ងារសុខភាពសត្វភូមិ បានយកចិត្តទុកដាក់ការពារ និងទប់ស្កាត់ការផ្ទុះ និងឆ្លងរាលដាលនៃជំងឺឆ្លងសត្វចិញ្ចឹមជាលក្ខណៈគ្រួសារ ដោយបានចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វសំខាន់ៗ នៅតាមតំបន់ដែលធ្លាប់ផ្ទុះ ក្នុងនោះមានជំងឺសារទឹក អុតក្តាម និងបូសខ្យល់ និងជំងឺបន្ទាប់បន្សំមួយចំនួនទៀត ដែលវ៉ាក់សាំងមួយចំនួនបានទទួលការគាំទ្រពីរាជរដ្ឋាភិបាល និងមួយចំនួនទៀតពីដៃគូអភិវឌ្ឍន៍ សម្រាប់ចាក់ការពារជំងឺឆ្លងលើគោ ក្របី ក្នុងនោះចាក់ការពារជំងឺសារទឹកគោក្របីបានចំនួន១,៤៩៦,៤១០ក្បាល ជំងឺអុតក្តាមគោក្របីចំនួន១៧៥,៤១០ក្បាល និងបូសខ្យល់គោក្របីចំនួន១៧,៤៥៧ក្បាល។ ( ឧបសម្ព័ន្ធទី ៨ និងទី ៩ )

ក្នុងកិច្ចបង្ការ ការពារការឆ្លងរាលដាលជំងឺសត្វនេះអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វបានជំរុញ ណែនាំ និងកិច្ចអន្តរាគមន៍ក្នុងការអនុវត្តជីវៈសុវត្ថិភាពក្នុងការចិញ្ចឹមសត្វ ដោយបានផ្សព្វផ្សាយ និងអនុវត្តផ្ទាល់នៅតាមសត្តឃាតដ្ឋាន តាមកសិដ្ឋានចិញ្ចឹម ពេលដឹកជញ្ជូនសត្វ និងផលិតផលសត្វ ទីកន្លែងផ្ទុះជំងឺសត្វ។ល។ សរុបបានចំនួន៣១.២២២លើក។

ការផ្តល់សេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ ក៏មានការចូលរួមយ៉ាងសកម្មពីភ្នាក់ងារសុខភាពសត្វភូមិ ដោយទទួលស្គាល់ពីគុណសម្បត្តិរបស់ភ្នាក់ងារសុខភាពសត្វភូមិដែលមិនមែនជាមន្ត្រីរដ្ឋាភិបាល តែ

ចូលរួមបម្រើសេវាកម្មបសុព្យាបាលជូនប្រជាកសិករក្នុងតម្លៃសមស្រប ដោយអង្គភាពជំនាញ សហការជាមួយអង្គការជាតិ និងអន្តរជាតិ និងដៃគូពាក់ព័ន្ធ យកចិត្តទុកដាក់ផ្តល់ការបំពាក់បំប៉ន និងជ្រើសរើសភ្នាក់ងារសុខភាពសត្វភូមិថ្មីបំពេញបន្ថែមជារៀងរាល់ឆ្នាំ។ ជាក់ស្តែងនៅឆ្នាំ២០១៦ តាមរយៈកម្មវិធីជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្នៈអនុវិស័យផលផល និងអនុវិស័យផលិតកម្មសត្វ-ផ្នែកផលិតកម្មសត្វ បានចុះកិច្ចសន្យាជាមួយអង្គការអ្នកក្សេត្រសាស្រ្ត និងពេទ្យសត្វគ្មានព្រំដែន ក្នុងការអនុវត្តគម្រោងស្តីពី «**ពេទ្យសត្វឆ្នើម**»។ គម្រោងនេះ អនុវត្តក្នុងខេត្តគោលដៅចំនួន៨ គឺពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ តាកែវ ព្រៃវែង ស្វាយរៀង បាត់ដំបង និងខេត្តកំពត។ សម្រាប់បណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិថ្មី២០០ នាក់ និងបំពាក់បំប៉នភ្នាក់ងារសុខភាពសត្វភូមិដែលមានស្រាប់១.៩០០នាក់។ ព្រមទាំងចងក្រងសហគមន៍ភ្នាក់ងារសុខភាពសត្វភូមិចំនួន១២ សហគមន៍។ ជាក់ស្តែងលទ្ធផលនៃការបំពាក់បំប៉នឡើងវិញក្នុងឆ្នាំ២០១៦ សរុបបានចំនួន៥២៦ នាក់។ ដោយកម្មវិធីរបស់រដ្ឋាភិបាលចំនួន២០០ នាក់ និងដោយអង្គការអ្នកក្សេត្រសាស្រ្ត និងពេទ្យសត្វគ្មានព្រំដែនចំនួន៣២៦នាក់។ ភ្នាក់ងារសុខភាពសត្វភូមិ៣២៦ នាក់នេះ បានទទួលការបណ្តុះបណ្តាលរំលឹកមេរៀនឡើងវិញទាក់ទងនឹងប៉ារាស៊ីត បច្ចេកទេសចិញ្ចឹមនិងជំងឺជ្រូក គោ និងមាន់ ព្រមទាំងការប្រើប្រាស់បសុឱសថ និងបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាទស្សនទានសុខភាពតែមួយ។ ភ្នាក់ងារសុខភាពសត្វភូមិថ្មីចំនួន២០០ នាក់ បានឆ្លងកាត់វគ្គទី១ ស្តីពីជំងឺប៉ារាស៊ីត ព្រមទាំងបានបង្កើតគណនេយ្យហៀសប៊ិកមួយឈ្មោះថាពេទ្យសត្វឆ្នើម។ បច្ចុប្បន្ននៅទូទាំងប្រទេសមានភ្នាក់ងារសុខភាពសត្វភូមិចំនួន១២.៨៨៨នាក់ ក្នុងនោះស្រ្តីចំនួន១.០៦២នាក់។(ឧបសម្ព័ន្ធទី ១០)

### គ-ការគ្រប់គ្រងគុណភាព សុវត្ថិភាព និងអនាម័យ

អង្គភាពបានត្រួតពិនិត្យ និងចេញវិញ្ញាបនបត្រអនាម័យសត្វ សាច់ និងផលិតផលសត្វ សម្រាប់ការនាំចេញ នាំចូល និងចរាចរណ៍លក់ក្នុងប្រទេស ព្រមទាំងបានបង្កើតក្រុមអន្តរាគមន៍ពិសេសរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងមន្រ្តីបសុពេទ្យរាជធានី-ខេត្ត ដោយសហការជាមួយអាជីវករសត្វ និងអ្នកពាក់ព័ន្ធមួយចំនួនទៀតក្នុងការត្រួតពិនិត្យ និងអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការត្រួតពិនិត្យអានាម័យសត្វ និងផលិតផលសត្វនិងទប់ស្កាត់ការលួចរត់ពន្ធសត្វ និងផលិតផលសត្វ ហើយត្រួត-ពិនិត្យបានចំនួន១១៨ករណី ណែនាំ និងធ្វើកិច្ចសន្យាបាន០៦ករណី និងផាកពិន័យចំនួន៤ ករណី ដោយផ្នែករាជនី-ខេត្ត ត្រួតពិនិត្យបាន៤៣ ករណី ផាកពិន័យ១០ករណី។

### ៣.២ការងារសុខភាពសាធារណៈ

កំណើនប្រជាជនជាមួយនឹងកំណើនប្រាក់ចំណូលបានជំរុញឲ្យតម្រូវការសាច់និងផលិតផលសត្វមានការកើនឡើង មិនត្រឹមតែបរិមាណ តែថែមទាំងគុណភាព និងអនាម័យទៀតផង។ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារបែបនេះ អង្គភាពជំនាញបានជំរុញមិនត្រឹមតែបង្កើនការផលិត តែក៏ជំរុញការគ្រប់គ្រងអនាម័យសត្វ សាច់ និងផលិតផលសត្វ។ ពាក់ព័ន្ធនឹងការងារនេះ អង្គភាពបានសិក្សាពីស្ថានភាពនៃការអនុវត្តអនាម័យសត្វនៅតាមកន្លែងពិឃាតសត្វ ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ផ្សព្វផ្សាយច្បាប់ និងលក្ខខណ្ឌតម្រូវអនាម័យ ផលប៉ះពាល់ និងការទទួលខុសត្រូវរបស់អាជីវករពាក់ព័ន្ធ។ លើសពីនេះ ក៏បានបង្កើនសមត្ថភាពជំនាញត្រួតពិនិត្យសុខភាពសត្វ អនាម័យសាច់ និងផលិតផលសត្វ នៅសត្តឃាតដ្ឋាន ដល់មន្រ្តីបសុពេទ្យប្រចាំការនៅសត្តឃាតដ្ឋានសរុប៧ វគ្គ មានអ្នកចូលរួមសរុប១២៧ នាក់ ក្នុងនោះស្រ្តី១៨ នាក់។ បានចុះត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការ

គ្រប់គ្រងសត្តឃាតដ្ឋានចំនួន២៤ លើក ព្រមទាំងបានរៀបចំសិក្ខាសាលាវាយតម្លៃការអនុវត្តស្តង់ដារអនាម័យសត្តឃាតដ្ឋាន ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធសរុប៥៤ ស្ត្រី១៥ នាក់។

ថ្វីបើអង្គភាពជំនាញបានជំរុញក្នុងការអនុវត្តច្បាប់ពាក់ព័ន្ធនានា ប៉ុន្តែការគ្រប់គ្រងសត្តឃាតដ្ឋាន នៅតែជួបបញ្ហាជាបន្តបន្ទាប់ដោយសារអាជីវករមិនទាន់យល់ពីច្បាប់ពាក់ព័ន្ធនឹងការវិនិយោគ និងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។ ការដែលមិនទាន់យល់នេះ បានបង្កផលវិបាកដល់សមត្ថកិច្ចផលិតកម្មនិងបសុព្យាបាល មិនត្រឹមតែក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនប៉ុណ្ណោះ ប៉ុន្តែប៉ះពាល់ដល់សុវត្ថិភាពសាច់ ការត្រួតពិនិត្យគុណភាព និងបាត់បង់ចំណូលបានពីការប្រមូលអាករត្រួតពិនិត្យអនាម័យផងដែរ។

ក្នុងចំណោមសត្តឃាតដ្ឋានទាំង១៥៥ កន្លែងនេះ មានតែសត្តឃាតដ្ឋានចំនួន៣១កន្លែងដែលអនុឡោមតាមអនុក្រឹត្យលេខ១០៨ អនក្រ.បក ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វសាច់ និងផលិតផលសត្វផង និងច្បាប់វិនិយោគផង។

តារាង និងក្រាហ្វិកខាងក្រោមបង្ហាញពីលទ្ធផលនៃការជំរុញការគ្រប់គ្រងសត្តឃាដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វសាច់ និងផលិតផលសត្វ ដែលពីមួយឆ្នាំទៅមួយឆ្នាំ ចំនួនសត្តឃាតដ្ឋានកើនឡើងជាលំដាប់ នៅឆ្នាំ២០១២ មាន១១៦ សត្តឃាតដ្ឋាន កើនដល់១៥៥ នៅឆ្នាំ២០១៦ កើន៣៤ សត្តឃាតដ្ឋាន ស្មើនឹង៣៤ %។

**ក្រាហ្វិកប្រៀបធៀបស្ថិតិសត្តឃាតដ្ឋានពីឆ្នាំ២០១២-២០១៦**




**តារាងប្រៀបធៀបសត្វពិឃាត និងតម្រូវការសាច់ឆ្នាំ២០១៦**

| ល.រ | ប្រភេទសត្វ | សត្វពិឃាត (ក្បាល) | តម្រូវការ (ក្បាល) | គម្លាត(ក្បាល) |
|---|---|---|---|---|
| ១ | គោ និងក្របី | ១២៨.៩០៤ | ៦៧៦.៧០១ | ៥៤៧.៧៩៧ |
| ២ | ជ្រូក | ៨៩៩.១០៨ | ៣.៦៦៩.៩៤៩ | ៣.៦៦៩.០៥៥ |
| ៣ | បក្សី | ១.០៣៣.៣៣៩ | | |

តាមរបាយការណ៍ពីបណ្តារាជធានី-ខេត្ត បានឲ្យដឹងថា នៅទូទាំងប្រទេសនៅក្នុងឆ្នាំ២០១៦ នេះ បានត្រួតពិនិត្យសត្វពិឃាត ក្នុងបរិមាណដូចមានបង្ហាញក្នុតារាងខាងលើ។

ចំនួនសត្វពិឃាតនេះ បើប្រៀបធៀបជាមួយនឹងតម្រូវការសាច់ដែលបានគណនាសម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ ត្រឹមតែ១៦,៣០ គីឡូក្រាម ឃើញថាមានចំនួនតិចជាងតម្រូវការ។ ទិន្នន័យនេះ មិនត្រឹមតែបញ្ជាក់ពីការបាត់បង់ចំណូលបង់ចូលថវិកាជាតិប៉ុណ្ណោះទេ តែថែមទាំងមិនបានត្រួតពិនិត្យគុណភាព សុវត្ថិភាពសាច់ អនាម័យដោយបសុពេទ្យ អាស្រ័យដោយសត្វមួយចំនួននៅតែបន្តពិឃាតនៅក្រៅសត្តឃាតដ្ឋាន ដែលបាន និងកំពុងមានផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់សុវត្ថិភាព និងគុណភាពសាច់។

ក្រាហ្វិកប្រៀបធៀបស្ថិតិសត្តឃាតដ្ឋាន និងសត្វពិឃាតឆ្នាំ២០១២-២០១៦




## ៤-ការផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម

### ៤.១ ការផ្សព្វផ្សាយបច្ចេកទេសផលិតកម្ម និងបសុព្យាបាល

ការផ្សព្វផ្សាយបច្ចេកទេសផលិតកម្ម និងបសុព្យាបាល បានអនុវត្តយ៉ាងសកម្ម ក្នុងការផ្ទេរចំណេះដឹង និងរបកគំហើញថ្មីៗជូនអ្នកពាក់ព័ន្ធ ទាំងការងារបច្ចេកទេស លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពពាក់ព័ន្ធនឹងការអភិវឌ្ឍអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។ ការផ្សព្វផ្សាយ បានអនុវត្តតាមរយៈកិច្ចប្រជុំ សិក្ខាសាលា ការចែកជូនឯកសារបោះពុម្ព វីដេអូឯកសារ ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ កិច្ចសំភាសន៍ តាមគេហទំព័រនិងការធ្វើបង្ហាញ។ជាលទ្ធផលនាឆ្នាំ២០១៦ នេះ អង្គភាពបាន៖

- បោះពុម្ព និងចែកចាយឯកសារចំនួន១០.០០០ ច្បាប់
- ផលិតវីដេអូឃ្លុតខ្លីចំនួន៣ ស្តីពីសកម្មភាពគាំទ្ររបស់សហភាពអឺរ៉ុបក្នុងការអភិវឌ្ឍអនុវិស័យបសុសត្វ វីដេអូស្តីពីអនាម័យសាច់ ការត្រួតពិនិត្យសុវត្ថិភាពសាច់សត្វ និងចរាចរសាច់សត្វនៅលើទីផ្សារ និងវីដេអូឃ្លុតខ្លីស្តីពីច្បាប់សុខភាពសត្វ និងផលិតកម្មសត្វ
- កម្មវិធីផ្សាយអត្ថបទបច្ចេកទេសតាមទូរទស្សន៍ជាតិកម្ពុជាចំនួន៥ អត្ថបទស្តីពី៖
    - សកម្មភាពគាំទ្ររបស់សហភាពអឺរ៉ុបក្នុងការអភិវឌ្ឍវិស័យបសុសត្វ
    - ដំណាំចំណីសត្វគោ ក្របី
    - បច្ចេកទេសបង្កាត់ពូជគោដោយសិប្បនិម្មិត
    - បច្ចេកទេសបង្កាត់ពូជជ្រូកដោយសិប្បនិម្មិត
    - បច្ចេកទេសចិញ្ចឹមជ្រូក មាន់ និងការផ្សំចំណីសត្វ
- ផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាលដល់កសិករចិញ្ចឹមសត្វចំនួន១៤៧៨ នាក់
- ធ្វើបង្ហាញពីការចិញ្ចឹមជ្រូកមេផលិតកូនចំនួន១០៦ បង្ហាញ
- ធ្វើបង្ហាញពីការចិញ្ចឹមមាន់ពូជក្នុងស្រុកចំនួន១១៦ បង្ហាញ
- ធ្វើបង្ហាញពីបច្ចេកទេសដាំ និងប្រើប្រាស់ដំណាំស្មៅចំណីសត្វចំនួន៦០ បង្ហាញ
- សិក្ខាសាលាផ្សព្វផ្សាយក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ

- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ផែនការ ឯកសារបច្ចេកទេស និងព័ត៌មានពាក់ព័ន្ធមួយចំនួនទៀតតាមគេហទំព័រ(www.maf.dahp.org)ដែលមានអ្នកចូលប្រើប្រាស់ប្រមាណជាង៣០.០០០នាក់។

លើសពីនេះ ដើម្បីលើកទឹកចិត្ត និងបង្កើនការផ្សព្វផ្សាយអំពីភាពជោគជ័យនៃការងារផលិតកម្ម និងបសុព្យាបាល អង្គភាពជំនាញបានរៀបចំកម្មវិធីប្រឡងជ្រើសរើសកសិករឆ្នើមក្នុងការចិញ្ចឹមសត្វ ជារៀងរាល់ឆ្នាំ កសិករឆ្នើមដែលមានលេខរៀងពី១ដល់៥បានទទួលរង្វាន់លើកទឹកចិត្ត និងបានចងក្រងលទ្ធផល និងបទពិសោធសម្រាប់ផ្សព្វផ្សាយបន្ត។ទីកន្លែងផលិតកម្មរបស់កសិករដែលទទួលបានជោគជ័យទាំង៥ និងទីកន្លែងដែលអនុវត្តល្អផ្សេងទៀត ត្រូវបានប្រើប្រាស់ជាកន្លែងសម្រាប់ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍រវាងកសិករ សហគមន៍ និងអ្នកពាក់ព័ន្ធហើយក៏បានផ្សព្វផ្សាយផងដែរតាមបណ្តាញព័ត៌មានសាធារណៈ។

## ៤.២ ការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានយកចិត្តទុកដាក់ក្នុងការកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាជាពិសេស ការអនុម័តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដែលជាមូលដ្ឋានសម្រាប់រៀបចំស្ថាប័ន និងគ្រប់គ្រងអនុវិស័យនេះក្នុងគោលដៅពង្រឹងការអនុវត្តស្តង់ដារអនាម័យលើផលិតផលសត្វ ការពង្រឹង និងជំរុញការអនុវត្តវិធានការអនាម័យសត្វ ភូតគាមអនាម័យ ដើម្បីបង្ការ ទប់ស្កាត់ និងលប់បំបាត់ការឆ្លងរាលដាលជំងឺសត្វ ក៏ដូចជាដើម្បីការពារសុខភាពសាធារណៈ។ ជាលទ្ធផល ច្បាប់ស្តីពីសុខ-ភាពសត្វ និងផលិតកម្មសត្វ ត្រូវអនុម័ត និងដាក់ឲ្យអនុវត្តនៅឆ្នាំ២០១៦។ ច្បាប់និងលិខិតបដ្ឋានគតិយុត្តមួយចំនួន ត្រូវបានផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធតាមរយៈសិក្ខាសាលា ប្រជុំផ្សព្វផ្សាយ បង្រៀននៅតាមគ្រិស្ថានបណ្តុះបណ្តាល ផ្សាយតាមប្រព័ន្ធព័ត៌មានសាធារណៈ វេទិកាតុមូល តាមគេហទំព័រ ចងក្រង និងបោះពុម្ភ ព្រមទាំងចែកជូនឯកសារទាំងនោះដល់អ្នកពាក់ព័ន្ធ។

# ៥-ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ

វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វមានតួនាទី អង្កេត តាមដាន សិក្សាស្រាវជ្រាវជំងឺសត្វ ពូជសត្វ ចំណីសត្វ បសុឱសថ បង្កើនសមត្ថភាពមន្ត្រីពាក់ព័ន្ធនឹងការងារពិសោធន៍ ស្រាវជ្រាវ ត្រួត-ពិនិត្យ តាមដាន វាយតម្លៃគុណភាព និងប្រសិទ្ធភាពការងារពិសោធន៍ស្រាវជ្រាវ និងសហការជាមួយមន្ទីរពិសោធន៍នានា អង្គការជាតិ និងអន្តរជាតិ លើការងារពិសោធន៍ ស្រាវជ្រាវ ពាក់ព័ន្ធនឹងសុខភាពសត្វ និងផលិតកម្មសត្វ។

ដើម្បីតាមដាន និងអន្តរាគមន៍ឆ្លើយតបទាន់ពេលវេលា វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ បានប្រមូលវត្ថុវិភាគជាប្រចាំ និងរាល់ករណីផ្ទុះជំងឺ វិភាគវត្ថុវិភាគទាំងនោះ។ ជាលទ្ធផលនាឆ្នាំ២០១៦នេះ បានប្រមូលវត្ថុវិភាគចំនួន៧.៦២៦វត្ថុវិភាគ ក្នុងនោះបានវិភាគរកមេរោគបង្កជំងឺនៅក្នុងផ្នែកវីរុសសាស្ត្របានចំនួន១.២០១វត្ថុវិភាគ ផ្នែកបាក់តេរីសាស្ត្របានចំនួន៣.១៤២វត្ថុវិភាគ ផ្នែកប៉ារ៉ាស៊ីតសាស្ត្របានចំនួន១.៦១៧វត្ថុវិភាគ ផ្នែកលោហិតសាស្ត្របានចំនួន១.៦២១វត្ថុវិភាគ និងផ្នែកសរីរៈរោគសាស្ត្របានចំនួន៤៥វត្ថុវិភាគ។ ផ្នែកអេពីដេមីសាស្ត្រ បានចុះប្រមូលពត៌មាននិងអង្កេតតាមដានស្រាវជ្រាវជំងឺឆ្លងសត្វមានជាអាទិ៍ ជំងឺអុតក្តាម សារទឹក ប៉េស្តជ្រូក ផ្តាសាយបក្សី និងជំងឺមួយចំនួនទៀត នៅតាមបណ្តារាជធានី-ខេត្ត ទូទាំងប្រទេស។

វិទ្យាស្ថានមានប្រព័ន្ធពត៌មានទាន់ហេតុការណ៍ សម្រាប់ទទួលព័ត៌មានពីម្ចាស់សត្វ និងអ្នកពាក់ព័ន្ធនានា។ វិទ្យាស្ថានជាសមាជិកនៃក្រុមការងារបច្ចេកទេសសម្រាប់ជំងឺស៊ូណូស និងបានចូលរួមប្រជុំពិភាក្សាជាមួយក្រសួងសុខាភិបាល អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) និងអង្គការសុខភាពពិភព

លោក (WHO) អំពីជំងឺផ្តាសាយបក្សី និងការរៀបចំផែនការជាតិ និងផែនការអនុវត្តសកម្មភាពសម្រាប់លុបបំបាត់ជំងឺផ្តែផ្តួតនៅកម្ពុជា។ ជាមួយគ្នានេះដែរ វិទ្យាស្ថានបានធ្វើការតាមដានឃ្លាំមើលជំងឺផ្តាសាយបក្សីប្រភេទ A/H5N1 នៅទីផ្សារក្នុងរាជធានីភ្នំពេញ និងខេត្តតាកែវ ដោយសហការជាមួយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា (IPC)។ លើសពីនេះទៀត វិទ្យាស្ថានក៏បានចូលរួមសហការក្នុងគម្រោងស្រាវជ្រាវជំងឺឆ្លងសត្វ ក៏ដូចជាជំងឺផ្តាសាយ ដូចជាគម្រោង LACANET, ISPH(ADB-SPS), Predict 2(USAID), EPT2 (USAID) និងកម្មវិធីបណ្តុះបណ្តាលអ្នកជំនាញផ្នែករោគរាតត្បាតសាស្ត្រ(CAVET2)។ បន្ថែមលើសពីនេះទៀត វិទ្យាស្ថានក៏បានបណ្តុះបណ្តាលមន្ត្រីផលិតកម្ម និងបសុព្យាបាលស្រុកនិងខេត្ត អំពីការអង្កេត តាមដាន និងស្រាវជ្រាវជំងឺនិងប្រជុំជាមួយមន្ត្រីជំនាញ និងអ្នកពាក់ព័ន្ធនៅក្នុងខេត្តកំពង់ចាម ព្រៃវែង សៀមរាប កែប កំពត ក្រចេះ កំពង់ធំ បន្ទាយមានជ័យ កំពង់ស្ពឺ ស្វាយរៀង ត្បូងឃ្មុំ កំពង់ឆ្នាំង និងខេត្តពោធិសាត់ ដែលមានអ្នកចូលរួមទាំងអស់ចំនួន១.០៣៩នាក់។ លទ្ធផលនៃការវិភាគ បានរកឃើញនូវប្រភេទវីរុសមួយចំនួន និងបានចាត់វិធានការបសុព្យាបាលបានទាន់ពេលវេលា។ វិទ្យាស្ថានក៏បាននិងកំពុងស្រាវជ្រាវការបង្កាត់ពូជក្នុងស្រុកតាមរយៈការប្រមូលមេជីវិតគោបាពូជក្នុងស្រុក វាយតម្លៃ បង្កក រក្សាទុក និងបង្កាត់សាកល្បងជាមួយគោមេពូជក្នុងស្រុក។

## V-ភាពសក្តានុពល និងបញ្ហាប្រឈម

កម្ពុជាមានសក្តានុពលអភិវឌ្ឍផលិតកម្មសត្វដោយហេតុថា កម្ពុជាមានទីតាំងភូមិសាស្ត្រយុទ្ធសាស្ត្រផ្សារភ្ជាប់ជាមួយបណ្តាប្រទេសអាស៊ាន និងអនុតំបន់ទន្លេមេគង្គក្នុងការអភិវឌ្ឍរចនាសម្ព័ន្ធ និងពង្រឹងបណ្តុំផលិតកម្មសម្រាប់ទីផ្សារក្នុងតំបន់និងអន្តរជាតិ។ ដោយមានការកើនឡើងនូវតម្រូវការប្រើប្រាស់សាច់ទាំងក្នុងនិងក្រៅស្រុកកត្តាប្រជារាស្ត្រដែលមានការកើនឡើងជារៀងរាល់ឆ្នាំ និងសម្បូរវត្ថុធាតុដើមសម្រាប់ផលិតចំណីសត្វរួមទាំងផ្ទៃដីកសិកម្មធំទូលាយមិនទាន់ប្រើប្រាស់អស់សក្តានុពលនៅឡើយ ការជំរុញអភិវឌ្ឍន៍ឧស្សាហកម្មសត្វគឺជាអនុវត្តនៃការព ពង្រឹងខ្សែសង្វាក់តម្លៃនៃផលិតកម្មកសិកម្ម។

ប៉ុន្តែស្របពេលជាមួយនឹងកាលនុវត្តភាពខាងលើ ការអភិវឌ្ឍអនុវិស័យនេះ ក៏ជួបនូវបញ្ហាប្រឈមមួយចំនួន ដូចជា៖

១. សមត្ថភាពនៃការប្រកួតប្រជែងទីផ្សារសត្វរស់ សាច់ និងផលិតផលនៅមានកម្រិត ព្រោះថ្លៃដើមនៃផលិតកម្មសត្វក្នុងស្រុកខ្ពស់ដែលកត្តានេះបណ្តាលមកពី៖

- អគ្គីសនីមានតម្លៃថ្លៃជាងប្រទេសជិតខាង
- ខ្វះលទ្ធភាពទទួលបានពូជសត្វដែលមានគុណភាពល្អ
- ការពឹងផ្អែកលើការនាំចូលទាំងចំណី សារធាតុបន្ថែមសម្រាប់លាយផ្សំចំណីសត្វ បសុឱសថ និងវ៉ាក់សាំង
- អត្រាឈឺងាប់សត្វនៅមានកម្រិតខ្ពស់
- បែបផែនផលិតកម្មខ្នាតតូច
- ខ្វះគោលនយោបាយផ្តល់ឥណទានអនុគ្រោះសម្រាប់ផលិតកម្មសត្វ ផលិតកម្មបសុឱសថ វ៉ាក់សាំង និងចំណីសត្វ
- ខ្វះហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផលិត និងកែច្នៃផលិតផលក្នុងស្រុកដូចជារោងចក្រផលិតចំណីសត្វ បសុឱសថ វ៉ាក់សាំង និងរោងចក្រ ឬ សិប្បកម្មកែច្នៃសាច់សត្វ។

